ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

## របាយការណ៍៖

# ស្ថានភាពសេរីភាពសារព័ត៌មាន នៅកម្ពុជា




ខែមេសា ឆ្នាំ២០២៤

**របាយការណ៍៖ ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា**

រៀបចំដោយ៖ ក្រសួងព័ត៌មាន © រក្សាសិទ្ធគ្រប់យ៉ាង

ចេញផ្សាយ ក្នុងខែមេសា ឆ្នាំ២០២៤ - រាជធានីភ្នំពេញ ប្រទេសកម្ពុជា
រូបភាពក្របខាងមុខដោយ៖
© លោក លន ហ្សាឌីណា / ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)
រូបភាពក្របខាងក្រោយដោយ៖
© លោក ខឹម សុវណ្ណារ៉ា / ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)

# របាយការណ៍

# «ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា»

រៀបចំដោយ ក្រសួងព័ត៌មាន ខែមេសា ឆ្នាំ២០២៤



# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ ៦

សាររបស់ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន ........ ៧

សារបាន ........ ៨

វិធីសាស្ត្រនៃការសិក្សា ........ ១២

សេចក្តីសង្ខេបលទ្ធផលនៃការស្ទង់មតិ ........ ១៤




**ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា** ........ ១៨
១. បច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ........ ១៩
២. ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាក្នុងបរិបទនៃបរិវត្តកម្មឌីជីថល ........ ២៣
៣. ស្ថានភាពសេរីភាពសារព័ត៌មានក្នុងក្របខណ្ឌច្បាប់ ........ ២៨
៤. ការស្ទង់មតិស្ដីពីស្ថានភាពសេរីភាពសារព័ត៌មានកម្ពុជា ........ ៣១
៥. កិច្ចគាំពារក្នុងវិស័យព័ត៌មាន និងសេវាសាធារណៈ ........ ៣៥
**សេចក្ដីសន្និដ្ឋាន** ........ ៤២
**អនុសាសន៍** ........ ៤៦
**ចក្ខុវិស័យគ្រប់គ្រងវិស័យព័ត៌មាននៅកម្ពុជា** ........ ៥០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន** សម្រាប់ការផ្តួចផ្តើម និងដឹកនាំការងារចងក្រងរបាយការណ៍នេះចាប់តាំងពីការចាប់ផ្តើមនៃការសិក្សារហូតដល់ការងារបញ្ចប់ និងសូមអរគុណចំពោះ ក្រុមការងាររៀបចំរបាយការណ៍ ក្រុមការងារប្រតិបត្តិផ្សព្វផ្សាយព័ត៌មានតាមអ៊ីនធឺណិតនិងឌីជីថលក្រសួងព័ត៌មាន បុគ្គលិកពាក់ព័ន្ធមកពីអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ ព្រមទាំងប្រធាន អនុប្រធាន មន្ត្រីនៃមន្ទីរព័ត៌មានរាជធានីខេត្តទាំងអស់ អ្នកសារព័ត៌មាន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានចូលរួម និងសហការយ៉ាងល្អ ក្នុងដំណើរការនៃការប្រមូលព័ត៌មាន ដើម្បីតាក់តែងរបាយការណ៍នេះឡើង។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះឥស្សរជន និងបុគ្គលសំខាន់ៗក្នុងវិស័យព័ត៌មាន ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមផ្តល់ជាទស្សនៈ និងមតិយោបល់ជុំវិញប្រធានបទនៃការសិក្សានេះ ដើម្បីធ្វើឱ្យរបាយការណ៍នេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

# សាររបស់ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន



របាយការណ៍ស្តីពី*ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា* ជារបាយការណ៍ដែលកម្ពុជាបានរៀបចំឡើងដោយខ្លួនឯងផ្ទាល់ ក្នុងក្របខណ្ឌនៃរាជរដ្ឋាភិបាលអាណត្តិទី៧នេះ ដោយផ្អែកលើទិន្នន័យដែលក្រសួងព័ត៌មានគ្រប់គ្រង និងការវាស់វែងពីស្ថានភាពរបស់អ្នកសារព័ត៌មានដែលប្រតិបត្តិការជាក់ស្តែងនៅតាមបណ្តារាជធានីខេត្តក្នុងប្រទេសកម្ពុជា ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃ។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងវិស័យព័ត៌មាន ស្របពេលដែលកម្ពុជា ក៏ដូចជាប្រទេសផ្សេងៗទៀតក្នុងតំបន់ បានបោះជំហានចូលដល់ចំណុចរបត់នៃបរិវត្តកម្មឌីជីថល និងខណៈពេលដែលរាជរដ្ឋាភិបាលអាណត្តិទី៧ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការលើកកម្ពស់សេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយបានពូនជ្រុំនូវរាល់សមិទ្ធផល និងស្នាដៃដឹកនាំក្នុងអាណត្តិមុនៗសម្រាប់វិស័យព័ត៌មានរបស់ **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងបច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** និង **ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**។ គឺនៅក្នុងបរិការណ៍នេះហើយដែលក្រសួងព័ត៌មានបានរៀបចំរបាយការណ៍ដ៏សំខាន់នេះឡើង ក្នុងគោលបំណងផ្តល់ព័ត៌មានស្តីពីស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា ដើម្បីផ្តល់ជាមូលដ្ឋានស្នូលសម្រាប់ការតម្រង់ទិសលើការគ្រប់គ្រង រៀបចំផែនការយុទ្ធសាស្ត្រ និងការអនុវត្តសកម្មភាពការងារក្នុងវិស័យសារព័ត៌មាន។

គិតចាប់តាំងពីខែសីហា ឆ្នាំ២០២៣ ដែលជាការចាប់ផ្តើមបន្តការងាររបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ក្រសួងព័ត៌មានបានបន្តបេសកកម្មដោយជំរុញការងារកំណែទម្រង់ និងពង្រឹងអភិបាលកិច្ចល្អ ដោយយកចិត្តទុកដាក់លើការធានានូវគុណភាព និងប្រសិទ្ធភាពការងារ ដើម្បីប្រែក្លាយក្រសួងព័ត៌មានជា *«ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាល ប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងគុណភាព»* ក្រោមទស្សនៈ *«ថ្មី ពិត លឿន និងទូលំទូលាយ ប្រកបដោយជំនឿទុកចិត្ត និងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន»* និងបានដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រចំនួន ៥ រួមមាន៖ *១.ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប, ២.ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ, ៣.ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ, ៤.ការរៀបចំប្រព័ន្ធ និងយន្តការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន និង ៥.ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព។*

ខ្ញុំមានជំនឿយ៉ាងមុតមាំថារបាយការណ៍ស្តីពី *ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា* នឹងក្លាយជាឯកសារដ៏សំខាន់មួយជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់តួអង្គ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជា យកទៅប្រើប្រាស់ជាអត្ថប្រយោជន៍ដល់បេសកកម្ម និងសកម្មភាពការងាររបស់ខ្លួន ដើម្បីបន្តចូលរួមលើកតម្កើងវិស័យព័ត៌មានកម្ពុជាឱ្យលេចត្រដែតសាកសមជាអំណាចទី៤ ដែលគាំទ្រនិងចូលរួមយ៉ាងសកម្មដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងថែរក្សា ការពារសុខសន្តិភាពនៅកម្ពុជា និងក្នុងតំបន់។

**នេត្រ ភក្ត្រា**

# សារពាន





*ថ្នាក់ដឹកនាំចុះពិនិត្យសកម្មភាពបំពេញការងាររបស់បុគ្គលិកទីភ្នាក់ងារសារព័ត៌មានកម្ពុជា ឬ SPK និងកាសែតកម្ពុជា*
*© បណ្ណសារទីភ្នាក់ងារសារព័ត៌មានកម្ពុជា* (AKP)

កាលពី៤៥ឆ្នាំមុន សិទ្ធិទទួលបាននូវព័ត៌មានរបស់ប្រជាពលរដ្ឋកម្ពុជាត្រូវបានប្រគល់ជូនប្រជាពលរដ្ឋវិញនៅពេលដែលប្រព័ន្ធផ្សព្វផ្សាយរដ្ឋបានចាប់បដិសន្ធិឡើងវិញនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ ពោលគឺទីភ្នាក់ងារសារព័ត៌មានកម្ពុជា ឬ SPK និងវិទ្យុសំឡេងប្រជាជនកម្ពុជា ត្រូវបានបង្កើតឡើងវិញមួយថ្ងៃក្រោយការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។ បន្ទាប់មក កាសែតកម្ពុជាក៏ត្រូវបានបង្កើតឡើងវិញផងដែរនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៩ ដើម្បីផ្តល់ព័ត៌មានជូនប្រជាជនកម្ពុជាក្នុងសម័យកាលនោះនិងមានដំណើរការរីកចម្រើនជាបន្តបន្ទាប់។

ក្នុងសម័យកាលក្រោយមកទៀត ដោយសារការផ្តល់តម្លៃខ្ពស់ដល់វិស័យព័ត៌មាន និងការបើកទូលាយនូវសិទ្ធិសេរីភាពសារព័ត៌មានពីសំណាក់ថ្នាក់ដឹកនាំរបស់រាជរដ្ឋាភិបាលពីមួយអាណត្តិទៅមួយអាណត្តិ ដោយឈរលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាបានរីកចម្រើនឡើងជាលំដាប់ ជាពិសេសក្នុងរយៈពេល ៣០ឆ្នាំ ចុងក្រោយនេះ ប្រកបដោយភាពចម្រុះនិងគ្រប់ទស្សនៈ ក្នុងការផ្តល់ព័ត៌មានទៅកាន់គ្រប់ទិសទី និងគ្រប់ពេលវេលា។

ប្រទេសកម្ពុជា ក៏ដូចជាប្រទេសដទៃទៀតក្នុងតំបន់ដែរ បានឈានជើងចូលដល់ចំណុចរបត់នៃការប្រែប្រួលស្ថានភាពក្នុងវិស័យសារព័ត៌មានក្នុងក្របខណ្ឌនៃបរិវត្តកម្មឌីជីថល និងការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យានៅលើពិភពលោក។ ការណ៍នេះ បានជំរុញឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើនទៅលើទិដ្ឋភាពទូទៅនៃប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា ជាក់ស្តែងការកើនឡើងគួរឱ្យកត់សម្គាល់នូវសារព័ត៌មានអនឡាញ និងអ្នកសារព័ត៌មានពលរដ្ឋ ដែលបានផ្តល់នូវជម្រើសបន្ថែមសម្រាប់ការទទួលព័ត៌មាន ហើយទន្ទឹមនេះវាទាមទារឱ្យប្រព័ន្ធផ្សព្វផ្សាយប្រពៃណីចាំបាច់

ត្រូវសម្របខ្លួនដោយការធ្វើសមាហរណកម្មបែបឌីជីថល រាប់បញ្ចូលទាំងប្រព័ន្ធប្រតិបត្តិការ ការអនុវត្តបែបផែននៃការងារ និងគំរូអាជីវកម្ម។ ម៉្យាងទៀត ការរីកដុះដាលយ៉ាងគំហុកនៃការផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិត និងលើបណ្តាញសង្គមគ្រប់ប្រភេទ ដែលមួយផ្នែកបណ្តាលមកពីការផ្លាស់ប្តូរជម្រើសសម្រាប់ការទទួលបានព័ត៌មានរបស់ប្រជាជននេះ បានជះឥទ្ធិពលអវិជ្ជមានមកលើប្រព័ន្ធផ្សព្វផ្សាយប្រពៃណី រួមមាន កាសែត ទស្សនាវដ្តី (print press) វិទ្យុ និងទូរទស្សន៍។ ឥទ្ធិពលអវិជ្ជមានទាំងនេះ បានធ្វើឱ្យមានការថមថយនូវចំនួនអ្នកអាន អ្នកទស្សនា និងអ្នកស្តាប់ ហើយបានប៉ះពាល់មួយផ្នែកដល់ប្រភពចំណូលដែលប្រព័ន្ធផ្សព្វផ្សាយប្រពៃណីធ្លាប់ទទួលបានពីការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផល ឬសេវាកម្មនានា។

ទិដ្ឋភាពសំខាន់ៗទាំងនេះបានក្លាយជាកម្មវត្ថុនៃការពិភាក្សាស្ទើរគ្រប់វេទិកាស្តីពីព័ត៌មាន ដែលវាបានបង្ហាញយ៉ាងច្បាស់អំពីសារៈសំខាន់នៃវិស័យសារព័ត៌មាននៅក្នុងសង្គមកម្ពុជា ហើយមានភាពស្របគ្នាទៅនឹងការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ការគោរពសិទ្ធិសេរីភាពសារព័ត៌មាន សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន ដូចបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងបរិបទនេះ ដើម្បីវាស់វែងពីសេរីភាពសារព័ត៌មាននៅកម្ពុជា ក្រសួងព័ត៌មានបានរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីអំពីស្ថានភាពនៃសេរីភាពសារព័ត៌មាន ដោយផ្អែកលើទិដ្ឋភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ភាពចម្រុះនិងសម្បូណ៌បែបនៃសារព័ត៌មាន និងស្ថានភាពនៃលំហប្រតិបត្តិវិជ្ជាជីវៈសារព័ត៌មាន។ ចក្ខុវិស័យដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងព័ត៌មានក្នុងអាណត្តិទី៧ក្នុងការគ្រប់គ្រងវិស័យព័ត៌មាន ក៏ជាធាតុស្នូលនៃរបាយការណ៍នេះផងដែរ រាប់បញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាក្នុងរយៈពេល៧ឆ្នាំចុងក្រោយ (ឆ្នាំ២០១៧ ដល់ ២០២៤) ក្នុងគោលបំណងធ្វើឱ្យវិស័យនេះកាន់តែមានភាពប្រសើរឡើងថែមទៀត ប្រកបដោយភាពចម្រុះ គុណភាព រស់រវើក រឹងមាំ និងសណ្តាប់ធ្នាប់ល្អ ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងការប្រតិបត្តិតួនាទីនិងភារកិច្ចប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវ។







សកម្មភាពបំពេញការងាររបស់បុគ្គលិកទីភ្នាក់ងារសារព័ត៌មានកម្ពុជា ឬ SPK និងកាសែតកម្ពុជា
© បណ្ណសារទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)

# វិធីសាស្ត្រ នៃការសិក្សា






*កិច្ចប្រជុំរវាងក្រុមការងាររៀបចំរបាយការណ៍នៃក្រសួងព័ត៌មានជាមួយតំណាងមន្ទីរព័ត៌មាន២៥រាជធានី-ខេត្ត*
*© អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន*

ដើម្បីស្វែងយល់ និងវាស់វែងស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា ក្រុមការងាររៀបចំរបាយការណ៍បានអនុវត្តវិធីសាស្ត្រចម្រុះ ដោយដាក់បញ្ចូលទាំងគុណវិស័យ និងបរិមាណវិស័យក្នុងបែបផែននៃការប្រមូលទិន្នន័យ៖

១. ការពិនិត្យលើឯកសារដែលមានស្រាប់ (Desk Review)។ ប្រភពព័ត៌មានសម្រាប់ការសិក្សារាប់បញ្ចូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

២. ការស្ទង់មតិត្រូវបានអនុវត្តដោយបានបញ្ជូនកម្រងសំណួរសរុបចំនួន ៣៥០ កម្រងសំណួរ ទៅកាន់អ្នកសារព័ត៌មានដែលត្រូវបានជ្រើសរើសដោយចៃដន្យ (Random Sampling) ចំនួន៣៥០នាក់ នៅក្នុង២៥រាជធានី-ខេត្ត។ កម្រងសំណួរត្រូវបានបែងចែកជាពីរផ្នែកធំៗ ដែលផ្នែកទី១ផ្តោតលើព័ត៌មានប្រជាសាស្ត្រ និងផ្នែកទី២ផ្តោតលើទស្សនៈអ្នកសារព័ត៌មានចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា។ អ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមក្នុងការស្ទង់មតិ បានបំពេញចម្លើយក្នុងកម្រងសំណួរដោយឯករាជ្យ អនាមិក ផ្អែកតាមឆន្ទៈនិងការយល់ឃើញផ្ទាល់ខ្លួន ដោយគ្មានការត្រួតពិនិត្យ ឬស្ថិតក្រោមឥទ្ធិពលរបស់ជនណាម្នាក់ឡើយ។ ក្រោយការបំពេញចប់ កម្រងសំណួរទាំងអស់ត្រូវបានប្រមូលមកវិញ សម្រាប់បម្រើដល់ការងារបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រនិងការវិភាគគ្រប់ជ្រុងជ្រោយ។ ក្នុងចំណោមកម្រងសំណួរដែលត្រូវបានអនុវត្ត កម្រងសំណួរយកជាការបានសម្រាប់ការវិភាគមានចំនួន៣៤១ កម្រងសំណួរ ។

៣. ការបង្ហាញទស្សនៈ និងផ្តល់មតិយោបល់ពីឥស្សរជន និងបុគ្គលជាន់ខ្ពស់សំខាន់ៗក្នុងវិស័យព័ត៌មាន។ បុគ្គលសំខាន់ៗក្នុងវិស័យព័ត៌មានរួមមានមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ប្រធានសមាគមអ្នកសារព័ត៌មាន ភ្នាក់ងារសារព័ត៌មានជាតិនិងបរទេស សារព័ត៌មានសហគមន៍ និងគ្រឹះស្ថានឧត្តមសិក្សា សរុបចំនួន១១រូប ដែលចូលរួមឆ្លើយនឹងសំណួរពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មាននៅកម្ពុជា។




# សេចក្តីសង្ខេប
# លទ្ធផលនៃការស្ទង់មតិ

# ព័ត៌មានអ្នកចូលរួមស្ទង់មតិ



អ្នកសារព័ត៌មានចំនួន
**៣៤១**នាក់
បានចូលរួមស្ទង់មតិ









អាយុជាមធ្យម
**៤២**ឆ្នាំ

## កម្រិតវប្បធម៌



ផ្អែកលើលទ្ធផលនៃការស្ទង់មតិ ការសិក្សាស្រាវជ្រាវបានកត់ត្រាទុកថា ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជាមានភាពល្អប្រសើរ ដោយក្នុងចំណោមអ្នកចូលរួមឆ្លើយក្នុងការស្ទង់មតិសរុបចំនួន ៣៤១នាក់ មានមនុស្សចំនួន ៧៩,៨% បានឆ្លើយថាសេរីភាពសារព័ត៌មាននៅកម្ពុជាមានភាពល្អប្រសើរ ដែលក្នុងនោះ ៧១% បានឆ្លើយថាសេរីភាពសារព័ត៌មាននៅកម្ពុជាមានស្ថានភាពល្អ និង ៨,៨% បានឆ្លើយថាសេរីភាពសារព័ត៌មានមានស្ថានភាពល្អបំផុត។ ផ្អែកតាមលទ្ធផលនៃការស្ទង់មតិនេះ មនុស្សចំនួន ៩៥% ក្នុងចំណោមអ្នកចូលរួមឆ្លើយក្នុងការស្ទង់មតិទាំងអស់ បានឯកភាពថា ប្រព័ន្ធផ្សព្វផ្សាយសម្បូណ៍បែបនៅកម្ពុជាបច្ចុប្បន្ន គឺជាការចូលរួមលើកកម្ពស់សេរីភាពសារព័ត៌មាន ហើយមនុស្សចំនួន ៧៩,៨% បានអះអាងថាខ្លួនមានសេរីភាពពេញលេញក្នុងការប្រកបអាជីពជាអ្នកសារព័ត៌មាន ដោយមានភាពងាយស្រួល និងសុវត្ថិភាពក្នុងការប្រមូលព័ត៌មានពីប្រភពផ្សេងៗសម្រាប់ការសរសេរផលិត និងផ្សព្វផ្សាយព័ត៌មានរបស់ខ្លួនដោយសេរី។ ទន្ទឹមនេះ មនុស្សចំនួនស្ទើរតែ ១០០% នៃចំនួនអ្នកឆ្លើយនឹងការស្ទង់មតិសរុប បានផ្តល់សារៈសំខាន់ដល់ការគោរពក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានដែលពួកគេបានប្រកាន់ខ្ជាប់ក្នុងអាជីពជាអ្នកសារព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាបានរកឃើញថាក្នុងចំណោមអ្នកស្ទង់មតិសរុបចំនួន៣៤១នាក់ មានមនុស្សចំនួនត្រឹម ៣៣,៣% មានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ហើយអ្នកសារព័ត៌មានដែលបានទទួលការបណ្តុះបណ្តាលជំនាញសារព័ត៌មានពីមហាវិទ្យាល័យ មានចំនួនត្រឹម ២,២៥% ប៉ុណ្ណោះ។



*សម្តេចធិបតីចូលរួមក្នុងពិធីជំនួបជាមួយនឹងអ្នកប្រើប្រាស់បណ្តាញសង្គមកាលពីខែកក្កដា ឆ្នាំ២០២៣ កន្លងទៅ* © STPM

## អ្នកសារព័ត៌មាន

**៣៤១នាក់**
**ទូទាំងប្រទេសចូលរួម**
**ក្នុងការស្ទង់មតិ**

**៧៩.៨%**

**យល់ថា សេរីភាពសារព័ត៌មាន**
**នៅកម្ពុជាមានលក្ខណៈល្អប្រសើរ**




*ឯកឧត្តម នេត្រ ភក្ត្រា ផ្តល់ព័ត៌មានជូនអ្នកសារព័ត៌មាននាពេលកន្លងទៅ© យូសុះ អាប់ឌុលរ៉ាហ៊ីម*




# ស្ថានភាពសេរីភាព
# សារព័ត៌មាននៅកម្ពុជា



*អ្នកសារព័ត៌មានជាតិ និងអន្តរជាតិក្នុងកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២ ដែលកម្ពុជាជាម្ចាស់ផ្ទះ*
*© ទីភ្នាក់ងារសារព័ត៌មានកម្ពុជា* (AKP)

## ១. បច្ចុប្បន្នភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា

ក្នុងក្របខណ្ឌនៃការលើកកម្ពស់សិទ្ធិសេរីភាពសារព័ត៌មាន ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពប្រព័ន្ធផ្សព្វផ្សាយជាបេសកកម្មដ៏ចម្បងមួយរបស់ក្រសួងព័ត៌មាន ដោយក្នុងនោះទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP) វិទ្យុជាតិកម្ពុជា(RNK) ទូរទស្សន៍ជាតិកម្ពុជា(TVK) និងប្រព័ន្ធផ្សព្វផ្សាយឯកជន បាននិងកំពុងដើរតួនាទីយ៉ាងសកម្មក្នុងការផ្តល់ព័ត៌មាន ចំណេះដឹងនិងការកម្សាន្តជូនដល់ប្រជាពលរដ្ឋទាំងនៅក្នុងប្រទេសកម្ពុជា និងលើពិភពលោក។ មិនតែប៉ុណ្ណោះ កាសែតកម្ពុជា ដែលជាសារព័ត៌មានបោះពុម្ពរបស់រដ្ឋត្រូវបានបង្កើតឡើងដំបូងគេបង្អស់នៅឆ្នាំ១៩៧៩ ត្រូវបានរៀបចំដាក់ឱ្យចេញផ្សាយឡើងវិញកាលពីនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ ខណៈពេលប្រព័ន្ធផ្សព្វផ្សាយបុរាណមួយចំនួនកំពុងប្រឈមនឹងការលំបាក ដោយខ្លះបានបញ្ឈប់ដំណើរការផលិតព័ត៌មានរបស់ខ្លួន និងមួយចំនួនទៀតបានបិទទ្វារទៅហើយ។

បច្ចុប្បន្ន កាសែតកម្ពុជា ដែលមានវ័យ ៤៥ឆ្នាំ ហើយ ត្រូវបានដាក់ឱ្យមានដំណើរការឡើងវិញក្នុងនាមជាសារព័ត៌មានជាតិ សម្រាប់ជាសំឡេងរបស់ជាតិ ពាំនាំព័ត៌មានពិតអំពីកម្ពុជាជូនដល់ប្រជាជននៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងលើពិភពលោក។

ទន្ទឹមនេះ ក្រសួងព័ត៌មានបាន និងកំពុងបន្តលើកទឹកចិត្តការបំពេញតួនាទី និងការចូលរួមពីសំណាក់វិស័យឯកជនក្នុងការផ្សព្វផ្សាយព័ត៌មានដល់ប្រជាជននៅទូទាំងប្រទេស ឱ្យស្របទៅនឹងតម្រូវការ និងការវិវត្តរបស់សង្គម។ ស្របពេលដែលមធ្យោបាយនៃការផ្សព្វផ្សាយមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាពិសេសការរីកចម្រើននៃបណ្តាញទំនាក់ទំនងសង្គម ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ក៏ដូចជាឯកជន បានបង្កើនលទ្ធភាព និងសមត្ថភាពផ្សាយព័ត៌មានរបស់ខ្លួនតាមបណ្តាញទំនាក់ទំនងសង្គមមានដូចជា៖ ហ្វេសប៊ុក(Facebook) ឆាណែលតេឡេក្រាម(Telegram)

យូធូប( YouTube ) ទ្វីតធ័រ( Twitter ) តិកតុក( TikTok ) និង អ៊ីនស្តាក្រាម( Instagram )បន្ថែមលើការផ្សព្វផ្សាយព័ត៌មានតាមរយៈគេហទំព័រ និងកម្មវិធីក្នុងឧបករណ៍ឆ្លាតវៃ( App ) បានយ៉ាងទូលំទូលាយថែមទៀតផង។ ជាងនេះទៀត ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជន បានបន្តពង្រឹងគុណភាព និងប្រសិទ្ធភាពផ្សាយកម្មវិធីព័ត៌មាន ការសន្ទនាមតិ និងកម្មវិធីសិល្បៈកម្សាន្តនានា គ្រប់ទម្រង់ជាច្រើនផ្សេងទៀត ដើម្បីបង្កើនការទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ ជាព័ត៌មានសំឡេង អត្ថបទ និងរូបភាព ហើយជំរុញសន្ទុះនៃការផ្សាយរបស់ខ្លួនឱ្យស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា និងតម្រូវការក្នុងសង្គមនាពេលបច្ចុប្បន្ន។

ទិន្នន័យបច្ចុប្បន្នភាពឆ្នាំ២០២៣របស់ក្រសួងព័ត៌មានបានបង្ហាញថា ក្រសួងបានចេញបណ្ណសម្គាល់អ្នកសារព័ត៌មានសរុប ចំនួន ៣,២០១បណ្ណ ក្នុងនោះបណ្ណអន្តរជាតិចំនួន ១១៣បណ្ណ ហើយអ្នកសារព័ត៌មានជាស្ត្រីមានចំនួន២៦៩ រូប គឺស្មើនឹង ៨,៧% នៃចំនួនអ្នកសារព័ត៌មានសរុប។ បច្ចុប្បន្ន ប្រព័ន្ធផ្សព្វផ្សាយទាំងប្រពៃណីនិងទំនើប ដែលបានចុះបញ្ជិកានៅក្រសួងព័ត៌មាន មានចំនួនជាង ២,០០០ រួមមាន៖ គេហទំព័រ និងទូរទស្សន៍អនឡាញ ( TV Online )មានចំនួន ៩៣៣ អង្គភាព, កាសែត ៤៤៧ អង្គភាព, សមាគមសារព័ត៌មាន ៥២ អង្គភាព, ទស្សនាវដ្តី ១៩៤ អង្គភាព, ព្រឹត្តិបត្រ ២១ អង្គភាព, រោងពុម្ព ១១៣ អង្គភាព, សៀវភៅ ២២ អង្គភាព, ទីភ្នាក់ងារសារព័ត៌មានបរទេស និងការិយាល័យតំណាង ២៧ អង្គភាព, ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម ០២ អង្គភាព, ស្ថានីយវិទ្យុ FM រាជធានីភ្នំពេញនិងខេត្ត ២៨៣ និងវិទ្យុ AM ភ្នំពេញ ០១ អង្គភាព, ទូរទស្សន៍ផ្សាយផ្ទាល់ ១៩ ស្ថានីយ និងផ្សាយបន្ត ១៦៥ ស្ថានីយ, ទូរទស្សន៍ឌីជីថល ១២ ស្ថានីយ និងទូរទស្សន៍អនឡាញ ១០ ស្ថានីយ, ទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ និងនៅតាមខេត្ត ៤៤ ស្ថានីយ និងទូរទស្សន៍អាណាឡូកមានចំនួន ១៤៣ ស្ថានីយ, ប្រព័ន្ធ OTT ( Over The Top ) ០៨ ស្ថានីយ និងប្រព័ន្ធ Satellite ចំនួន ០២។ នៅកម្ពុជា មានអ្នកសារព័ត៌មានចំនួនប្រមាណ មួយម៉ឺននាក់។ នៅដើមឆ្នាំ២០២៤នេះ ក្រសួងព័ត៌មានបានបន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយ និងការផ្តល់បណ្ណសម្គាល់អត្តសញ្ញាណដល់អ្នកសារព័ត៌មានក្នុងគោលបំណងរៀបចំសណ្តាប់ធ្នាប់ក្នុងវិស័យនេះឱ្យបានល្អ។



លោក **ណាង ដឺលុច**
បណ្ណាធិការនៃសារព័ត៌មានថ្មីៗ

“នៅក្នុងទិដ្ឋភាពរួម កម្ពុជាមានលំហសេរីភាពសារព័ត៌មានធំតាមរយៈការបង្កលក្ខណៈងាយស្រួលដល់ការបង្កើតក្រុមហ៊ុនព័ត៌មាន វត្តមាននៃការបញ្ចេញមតិដោយសេរីនៅតាមបណ្តាញទំនាក់ទំនងសាធារណៈ មានលំហូ ព័ត៌មានទូលំទូលាយពីរដ្ឋាភិបាលមកប្រជាពលរដ្ឋ និងពីប្រជាពលរដ្ឋទៅរដ្ឋាភិបាល។ ទោះយ៉ាងណាក៏ដោយ លំហ ឬសេរីភាពសារព័ត៌មាននៅកម្ពុជា នៅតែត្រូវបានរំខានដោយចំណុចអសកម្មមួយចំនួន ដែលកំពុងទាញ ចុះនូវគុណតម្លៃនៃសេរីភាពសារព័ត៌មាន។”

# បច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា

## ស្ថានីយទូរទស្សន៍

| | |
|---|---|
| ទូរទស្សន៍អាណាឡូក (Analog TV) | ១៤៣ |
| ទូរទស្សន៍ផ្សាយផ្ទាល់ (Main TV) | ១៩ |
| ទូរទស្សន៍ផ្សាយបន្ត (Relay TV) | ១៦៥ |
| ទូរទស្សន៍ឌីជីថល (Digital TV) | ១២ |
| ទូរទស្សន៍ខ្សែកាប (Cable TV) | ៤៤ |
| ទូរទស្សន៍ផ្សាយតាមផ្កាយរណប (Satelite TV) | ០២ |
| ទូរទស្សន៍ប្រព័ន្ធ Over the Top (OTT) | ០៨ |

**ទស្សនាវដ្ដី**
១៩៤ អង្គភាព

**គេហទំព័រ និងទូរទស្សន៍អនឡាញ**
(TV Online)
៩៣៣ អង្គភាព

**កាសែត**
៤៤៧ អង្គភាព

**ស្ថានីយវិទ្យុ**
FM ២៨៣ ស្ថានីយ
AM ០១ ស្ថានីយ

**ទីភ្នាក់ងារសារព័ត៌មានបរទេស**
២៧ អង្គភាព

**ព្រឹត្តិបត្រ**
២១ អង្គភាព

**សមាគមអ្នកសារព័ត៌មាន**
៥២ អង្គភាព

**បណ្ណសារព័ត៌មាន**
៣,២០១ បណ្ណ

**រោងពុម្ព**
១១៣ អង្គភាព

**សៀវភៅ**
២២ អង្គភាព

**ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម**
០២ អង្គភាព

ឯកឧត្តម **ប៉ែន បូណា**
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាអ្នកនាំពាក្យរាជរដ្ឋាភិបាល



“ នៅកម្ពុជា សេរីភាពសារព័ត៌មានរីកចម្រើនយ៉ាងខ្លាំងមិនធ្លាប់មានពីមុន។ ចំនួនស្ថាប័នសារព័ត៌មាននិងអ្នកសារព័ត៌មានកើនឡើងយ៉ាងគំហុកគួរឲ្យកត់សម្គាល់។ ប្រជាពលរដ្ឋមានប្រភពព័ត៌មានយ៉ាងសម្បូរបែបនិងមានជម្រើសទូលំទូលាយនិងងាយស្រួលក្នុងការទទួលបានព័ត៌មានលឿនរហ័ស។ រាជរដ្ឋាភិបាលផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់វិស័យសារព័ត៌មាន។ ប៉ុន្តែគុណភាពវិជ្ជាជីវៈសារព័ត៌មាននៅកម្ពុជារីកលូតលាស់យឺតជាងបរិមាណដែលនាំឱ្យកើតជាបញ្ហាប្រឈមមួយចំនួននៅក្នុងវិស័យនេះ។ កង្វះគុណភាពវិជ្ជាជីវៈរបស់អ្នកសារព័ត៌មានមួយចំនួន និងការយកសារព័ត៌មានជាឡប់ឡែបម្រើរបៀបវារៈនយោបាយពីសំណាក់ក្រុមជ្រុលនិយមមួយចំនួនបានធ្វើឱ្យសេចក្តីរាយការណ៍ព័ត៌មានមួយចំនួនប្រាសចាកពីគន្លងក្រមសីលធម៌វិជ្ជាជីវៈ និងរហូតដល់បំពានច្បាប់ បំពានអ្នកដទៃ បំភ្លៃការពិត ក្នុងចេតនាទុច្ចរិតដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពព័ត៌មាន និងតម្លៃរបស់សារព័ត៌មាន។ ”

ផ្អែកតាមទិន្នន័យស្ថិតិរបស់ក្រសួងព័ត៌មានក្នុងរយៈពេលប្រាំពីរឆ្នាំចុងក្រោយនេះ ពុំមានអ្នកសារព័ត៌មានណាម្នាក់ទទួលមរណភាព ឬទទួលពិន័យជាប្រាក់ឬជាប់ពន្ធនាគារដោយសារការបំពេញតួនាទី និងភារកិច្ចស្របច្បាប់ និងតាមក្រមសីលធម៌ជាអ្នកសារព័ត៌មាននោះទេ។ ប៉ុន្តែក្រសួងព័ត៌មានកត់សម្គាល់ឃើញថាក្រុមជនមួយចំនួនដែលជ្រកក្រោមស្លាកសារព័ត៌មាន បានប្រព្រឹត្តខុសក្រមសីលធម៌ និងយកអាជីពសារព័ត៌មានធ្វើជាមុខរបរដើម្បីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន ហើយពេលខ្លះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌពីបទកំហែងទារប្រាក់ និងបទល្មើសផ្សេងទៀតដែលមិនស្ថិតក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន។ ក្នុងករណីនេះ គេមិនត្រូវបកស្រាយថាវាជាការរំលោភបំពានសេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិឡើយ។ យោងតាមទិន្នន័យស្ថិតិដដែលនេះ អតីតអ្នកសារព័ត៌មាន និងមន្ត្រីក្រសួងព័ត៌មានសរុបចំនួន ៣៤ រូប បានទទួលមរណភាពដោយជរាពាធ និងជំងឺផ្សេងៗ។ ក្នុងការគ្រប់គ្រងអង្គភាពសារព័ត៌មាន និងពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ក្រសួងបានប្រកាសលុបឈ្មោះអង្គភាពសារព័ត៌មានចេញពីបញ្ជីចំនួន ២០អង្គភាព ក្នុងចន្លោះឆ្នាំ២០២០ ដល់ឆ្នាំ២០២៣ ដោយមូលហេតុអង្គភាពទាំងនោះបានបំពានក្រមសីលធម៌វិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ទន្ទឹមនឹងនេះ ក្រសួងព័ត៌មានបានអនុវត្តនីតិវិធីរដ្ឋបាល ដោយបានកោះហៅអ្នកពាក់ព័ន្ធក្នុងការប្រព្រឹត្តកំហុសវិជ្ជាជីវៈសារព័ត៌មាន ដើម្បីអប់រំណែនាំ និងធ្វើកិច្ចសន្យាឱ្យបញ្ឈប់ទង្វើខុសឆ្គងទាំងនោះសរុបចំនួនជាង ៥០ករណី។

# ទិន្នន័យស្ថិតិផ្សេងៗ



**៣៤ រូប**

ស្លាប់ដោយជរាពាធ និងជំងឺផ្សេងៗ

**៥០ ករណី**

ទទួលបានការណែនាំពីក្រសួង និងធ្វើកិច្ចសន្យា
បញ្ឈប់ការប្រព្រឹត្តកំហុសវិជ្ជាជីវៈសារព័ត៌មាន





**២០ អង្គភាព**

ត្រូវបានក្រសួងលុបឈ្មោះ ចេញពីបញ្ជី ដោយការបំពាន
ក្រមសីលធម៌វិជ្ជាជីវៈធ្ងន់ធ្ងរនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន
ក្នុងចន្លោះឆ្នាំ២០២០ និងឆ្នាំ២០២៣

## ២. ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាក្នុងបរិបទនៃបរិវត្តកម្មឌីជីថល

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ វត្តមាននៃប្រព័ន្ធឌីជីថល និងវឌ្ឍនភាពឥតឈប់ឈរនៃបច្ចេកវិទ្យាទំនើបបានបង្កឱ្យមានការផ្លាស់ប្តូរជាច្រើនក្នុងសង្គមកម្ពុជា និងពិភពលោក ជាពិសេសនៅក្នុងវិស័យព័ត៌មាន និងសោតទស្សន៍។ បច្ចេកវិទ្យាទំនើបបានបង្កើតជាឱកាសថ្មីៗ ផ្តល់លក្ខណៈអំណោយផល និងភាពងាយស្រួលជាងមុន ទាំងចំពោះអ្នកប្រើប្រាស់ និងប្រតិបត្តិករវិស័យសារព័ត៌មាន ដោយបានជំរុញវិសាលភាពក្នុងការទទួល និងផ្សព្វផ្សាយព័ត៌មានបានទូលំទូលាយ និងមានភាពច្នៃប្រឌិត។ ដូចបណ្តាប្រទេសផ្សេងៗទៀតក្នុងតំបន់ដែរ សង្គមកម្ពុជាកំពុងសម្របខ្លួនទៅនឹងឥទ្ធិពលនៃយុគសម័យឌីជីថល និងការវិវត្តដ៏លឿននៃបច្ចេកវិទ្យា។ ចំណូលចិត្តរបស់ប្រជាជនលើបច្ចេកវិទ្យាទំនើប និងកំណើននៃការប្រើប្រាស់អ៊ីនធឺណេតនៅកម្ពុជា បានផ្លាស់ប្តូរទម្លាប់របស់ប្រជាជនភាគច្រើនក្នុងការទទួលព័ត៌មាន ពោលគឺផ្លាស់ប្តូររបៀបពីការទទួលព័ត៌មានដោយការស្តាប់វិទ្យុ ការមើលទូរទស្សន៍ ការអានកាសែត ព្រឹត្តិបត្រ ឬទស្សនាវដ្តី ដែលជាប្រព័ន្ធផ្សព្វផ្សាយបុរាណ ទៅជាការទទួលព័ត៌មានលើប្រព័ន្ធផ្សព្វផ្សាយទំនើប ជាពិសេសលើបណ្តាញទំនាក់ទំនងសង្គម ដែលបញ្ជូនព័ត៌មានតាមរយៈទូរស័ព្ទទំនើបឬស្មាតហ្វូន (Smart phone) អាយផេត (iPad) កុំព្យូទ័រ ឬឧបករណ៍ទំនាក់ទំនងទំនើបផ្សេងទៀត ដើម្បីទទួលបានព័ត៌មានប្រចាំថ្ងៃ។




បណ្តាញសង្គមឈានមុខ
នៅកម្ពុជាក្នុងឆ្នាំ២០២៣




ចំនួនអ្នកប្រើប្រាស់បណ្តាញសង្គម
នៅកម្ពុជាពីឆ្នាំ២០១៧-២០២៣

គិតត្រឹមចុងឆ្នាំ២០២៣ កម្ពុជាមានអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមសរុបចំនួនប្រមាណជាង ១១លាននាក់* គឺស្មើនឹងប្រមាណជា ៦៨% នៃចំនួនប្រជាជនសរុប ហើយក្នុងចំណោមនោះ ហ្វេសប៊ុកជាបណ្តាញទំនាក់ទំនងសង្គមឈានមុខគេ ដែលមានអ្នកប្រើប្រាស់សរុបចំនួនជាង ១៣ លាននាក់** គឺស្មើនឹងប្រមាណជាង ៧៥% នៃចំនួនប្រជាជនសរុប។ ក្រៅពីហ្វេសប៊ុក តេឡេក្រាម ដែលមានអ្នកប្រើប្រាស់ប្រមាណ ១០លាននាក់ បាននិងកំពុងដើរតួនាទីជាបណ្តាញចែកចាយព័ត៌មានដ៏មានប្រជាប្រិយភាពមួយនៅកម្ពុជា បន្ថែមលើមុខងារផ្ញើសាររបស់វា។ តិកតុក (TikTok) ជាបណ្តាញទំនាក់ទំនងសង្គមមួយប្រភេទទៀត ដែលប្រជាប្រិយភាពកំពុងកើនឡើង ដោយមានអ្នកប្រើប្រាស់ ៧,៦លាននាក់ គិតត្រឹមដើមឆ្នាំ២០២៣។

ឯកឧត្តម **ឃឹម ឱត្ថិ**
អគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា



“ រាជរដ្ឋាភិបាលបានប្តេជ្ញាការពារសេរីភាពសារព័ត៌មាន សេរីភាពខាងការបញ្ចេញមតិស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីរបបសារព័ត៌មាន ពោលគឺទាំងអស់គ្នាត្រូវតែស្ថិតក្រោមតំបូលរដ្ឋធម្មនុញ្ញនិងច្បាប់របស់កម្ពុជា។ ដើម្បីឱ្យសេរីភាពសារព័ត៌មានកាន់តែប្រសើរឡើង ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដែលកំពុងដំណើរការ ត្រូវតែមានច្បាប់អនុញ្ញាតិប្រកបអាជីវកម្មពីក្រសួងព័ត៌មាន គួរតែផ្តល់វគ្គបណ្តុះបណ្តាលស្តីពីសារព័ត៌មាន ការរៀបចំសិក្ខាសាលាតម្រង់ទិស ដើម្បីពង្រឹងគុណភាពនៃការផ្សព្វផ្សាយ។ ករណីម្ចាស់អង្គភាពផ្សព្វផ្សាយបំពានច្បាប់ និងវិជ្ជាជីវៈ ក្រសួងគួរដកហូតអាជ្ញាបណ្ណ។ ”

*ទិន្នន័យពីDATAREPORTAL

**ទិន្នន័យពីNapoleoncat

ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមនៅប្រទេសកម្ពុជាមានភាពសម្បូណ៌បែប និងដោយសេរី ទាំងនេះក៏ដោយសារតែសិទ្ធិ និងសេរីភាពក្នុងការទទួលបាននូវសេវាកម្មផ្នែកអ៊ីនធឺណេតត្រូវបានបើកទូលាយ នៅទូទាំងផ្ទៃប្រទេសកម្ពុជា។ យោងតាមរបាយការណ៍របស់និយ័តករទូរគមនាគមន៍កម្ពុជា ទិន្នន័យអ្នកប្រើប្រាស់អ៊ីនធឺណេតនៅកម្ពុជា គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ មានចំនួនជាង ១៨លាននាក់។ ទិដ្ឋភាពទាំងនេះពិតជាបានផ្តល់ដល់សង្គមកម្ពុជាទាំងមូល នូវសេរីភាពក្នុងការទទួលបាននូវចំណេះដឹង និងប្រភពព័ត៌មានដ៏សម្បូណ៌បែប ព្រមទាំងភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នាកាន់តែឆាប់រហ័ស ទៅកាន់សមាជិកក្នុងគ្រួសារ ប្រជាជនក្នុងសហគមន៍ និងនៅលើពិភពលោក។

នៅក្នុងក្របខណ្ឌនៃកាលានុវត្តភាពថ្មីនេះ អង្គភាពសារព័ត៌មានប្រពៃណីបានរិះរកវិធីសាស្ត្រ និងបង្កើតគំនិតច្នៃប្រឌិតថ្មីក្នុងការពង្រឹងគុណភាព ប្រសិទ្ធភាពផ្សព្វផ្សាយ ក៏ដូចជាប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីធានាភាពប្រកួតប្រជែង និងនិរន្តរភាព សម្រាប់អង្គភាពរបស់ខ្លួន។ ស្របពេលជាមួយគ្នានេះ ប្រព័ន្ធផ្សព្វផ្សាយទំនើបក៏បានចាប់ផ្តើមមានសន្ទុះឡើងដែរ ដោយចំនួនភ្នាក់ងារ និងអង្គភាពសារព័ត៌មានអនឡាញបានកើនឡើងយ៉ាងគំហុកក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ លើសពីនេះទៀត ប្រជាជនដែលនិយមប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមខ្លាំងមួយចំនួន ថែមទាំងបានបង្កើតមាតិកាផ្សាយដោយខ្លួនឯង ដោយគ្រាន់តែប្រើទូរស័ព្ទទំនើប (ស្មាតហ្វូន) ជាមធ្យោបាយ សម្រាប់បម្រើចំណង់ចំណូលចិត្ត ឬតម្រូវការផ្ទាល់ខ្លួន ឬដើម្បីចែករំលែករឿងរ៉ាវរបស់ខ្លួនឯងផង និងហេតុការណ៍ពីក្នុងមូលដ្ឋានដែលខ្លួនរស់នៅផង។



លោក **ណុប វី**
នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

“ សេរីភាពសារព័ត៌មាននៅកម្ពុជាមានតិចតួច និងដោយអន្លើ។ ដើម្បីឱ្យសេរីភាពសារព័ត៌មាននៅកម្ពុជាកាន់តែល្អប្រសើរឡើង យើងទាំងអស់គ្នាគួររួមគ្នាពិនិត្យមើលលើច្បាប់នានាដែលកំពុងមានបច្ចុប្បន្នថាតើនៅមានចំណុចណាខ្លះជាចន្លោះប្រហោង ចំណុចណាខ្លះប៉ះពាល់ដល់ការអនុវត្ត និងចំណុចណាខ្លះគួរកែលំអដើម្បីធ្វើឱ្យប្រសើរឡើងនិងធានាបាននូវសេរីភាពសារព័ត៌មាន។ ភាពចាំបាច់ក្នុងការកសាងសមត្ថភាពដល់មន្ត្រីសាធារណៈក្នុងការឆ្លើយតបនឹងអ្នកសារព័ត៌មាន និងបង្កលក្ខណៈងាយស្រួលដើម្បីរួមគ្នាធ្វើការផ្សព្វផ្សាយព័ត៌មានពិតដល់សាធារណជន។ ជាងនេះទៅទៀត ក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានគួរត្រូវបានផ្សព្វផ្សាយនិងពង្រឹងឱ្យកាន់តែប្រសើរឡើង។ ”

បាតុភូតថ្មីទាំងនេះ ពិតជាបានបើកឱកាសឱ្យប្រជាជនមានជម្រើស និងភាពងាយស្រួលក្នុងការទទួលព័ត៌មាន ប៉ុន្តែវាក៏បានជះឥទ្ធិពលអវិជ្ជមាន និងបង្កផលវិបាកដល់ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី ជាឧទាហរណ៍ កាសែត ទស្សនាវដ្ដី វិទ្យុ និងទូរទស្សន៍ បានជួបប្រទះនឹងការថមថយនូវចំនួនអ្នកអាន អ្នកទស្សនា និងអ្នកស្ដាប់ ដែលជាហេតុធ្វើឱ្យបាត់ចំណូលមួយផ្នែកដែលប្រព័ន្ធផ្សព្វផ្សាយប្រពៃណី ធ្លាប់បានទទួលពីការផ្សាយពាណិជ្ជកម្មផលិតផល ឬសេវាកម្មនានា។ ជាងនេះទៀត ប្រជាជន ជាពិសេសអ្នកប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ មិនបានត្រៀមខ្លួនជាមុនឡើយ ប្រឈមនឹងការចូលមកដល់ និងអភិវឌ្ឍន៍ឥតឈប់ឈរនៃឧស្សាហកម្មឌីជីថល ជាពិសេសការវិវត្តរបស់បច្ចេកវិទ្យាចុងក្រោយ គឺបញ្ញាសិប្បនិម្មិត (Artificial Intelligence) ដែលផ្តល់ដល់មនុស្សទាំងគុណសម្បត្តិ និងគុណវិបត្តិ ជាពិសេសគឺគ្រោះថ្នាក់នៃព័ត៌មានក្លែងក្លាយ។ ជាក់ស្តែង តាមរយៈយន្តការអន្តរក្រសួង ក្រសួងព័ត៌មានបានកត់ត្រាទុកព័ត៌មានក្លែងក្លាយចំនួនជាង ៣,០០០ ករណី ក្នុងឆ្នាំ២០២៣ ដែលចំនួននេះមានការកើនឡើងប្រមាណ ១៦០% ក្នុងរយៈពេល ៤ឆ្នាំ ចុងក្រោយ ដោយក្នុងឆ្នាំ២០២០ ព័ត៌មានក្លែងក្លាយមានចំនួនត្រឹមជាង ១,៣០០ ករណីប៉ុណ្ណោះ។

គ្រោះថ្នាក់នៃព័ត៌មានក្លែងក្លាយបាន និងកំពុងបង្កផលវិបាកមកលើសង្គមរស់នៅរបស់យើងសព្វថ្ងៃ ដោយបានបង្កើតភាពច្របូកច្របល់ អាចបង្កភាពចលាចល ដែលនាំឱ្យដល់ការបាត់បង់ជំនឿទុកចិត្តក្នុងសង្គម។ រីឯអ្នកដែលរងគ្រោះត្រូវខាតបង់ពេលវេលា ថវិកា បាត់បង់កិត្តិយស ដោយសារការបង្ខូចកេរ្តិ៍ឈ្មោះ ក៏ដូចជាអាចប្រឈមនឹងហានិភ័យនៃអំពើឧក្រិដ្ឋផ្សេងៗជាដើម។ ជាងនេះទៀត គ្រោះថ្នាក់នៃព័ត៌មានក្លែងក្លាយអាចនឹងបង្កឱ្យមានការរើសអើង អភិភាពក្នុងសង្គម និងអាចប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិផងដែរ។




**៣,០០០**
**ករណីនៃព័ត៌មានក្លែងក្លាយ**
ត្រូវបានកត់ត្រាទុក ដោយក្រសួងព័ត៌មាន តាមរយៈយន្តការអន្តរក្រសួងក្នុងឆ្នាំ២០២៣

**កើនឡើង ១៦០%**
ក្នុងរយៈពេល៤ឆ្នាំចុងក្រោយ ឆ្នាំ២០២០
កត់ត្រាបាន **១,៣០០ ករណីនៃព័ត៌មានក្លែងក្លាយ**



**លោក ពុយ គា**
**ប្រធានក្លិបអ្នកកាសែតកម្ពុជា**

"ខ្ញុំបានបំពេញអាជីពជាអ្នកសារព័ត៌មាននេះអស់រយៈពេល30 ឆ្នាំហើយហើយខ្ញុំក៏មិនដែលមានបញ្ហាអ្វីដែរ។ ខ្ញុំមានសេរីភាពនៅក្នុងការបញ្ចេញមតិនិងការសរសេរផ្សព្វផ្សាយព័ត៌មានកន្លងមកនេះ ក៏ដោយសារខ្ញុំបានព្យាយាមគោរពវិជ្ជាជីវៈនិងក្រមសីលធម៌។ ខ្ញុំយល់ថាសេរីភាពសារព័ត៌មាននៅកម្ពុជានិងរក្សាបាននូវស្ថានភាពល្អបើសិនជាយើងនាំគ្នាពង្រឹងក្រមសីលធម៌និងគោរពវិជ្ជាជីវៈរបស់យើងឱ្យបានខ្ជាប់ខ្ជួន។ ទន្ទឹមនឹងនេះ យើងក៏ត្រូវបន្តស្វែងយល់ ដកស្រង់បទពិសោធន៍ និងរៀនសូត្របន្ថែមទៀតនូវការវិវត្តន៍ថ្មីៗនៃវិស័យព័ត៌មានពីប្រទេសផ្សេងៗ ជាពិសេសប្រទេសលោកខាងលិច។"



**លោក ពេញ ផេង**
**តំណាងវិទ្យុវាយោអេហ្វអឹម**

"សេរីភាពសារព័ត៌មាននៅកម្ពុជាមានភាពល្អប្រសើរច្រើន ប៉ុន្តែទាមទារឱ្យភាគីពាក់ព័ន្ធ យកចិត្តទុកដាក់បន្ថែមទៅលើសេរីភាពនៃការផ្សព្វផ្សាយដើម្បីឱ្យកាន់តែទូលំទូលាយពោលគឺអាចផ្សព្វផ្សាយពីគ្រប់បញ្ហាទាំងអស់ដែលបម្រើឱ្យផលប្រយោជន៍សាធារណៈដោយគ្មានការភ័យខ្លាច។ ដើម្បីលើកកម្ពស់សេរីភាពសារព័ត៌មាននៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង អ្នកសារព័ត៌មានត្រូវតែពង្រឹងសមត្ថភាព ជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌ឱ្យដល់កម្រិតអាជីព ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយត្រូវតែចូលរួមជួយជ្រោមជ្រែងអ្នកសារព័ត៌មានឱ្យមានលទ្ធភាពទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងក្រមសីលធម៌បន្ថែម។ ប្រជាពលរដ្ឋគួរចេះជ្រើសរើសប្រភពព័ត៌មាន ដើម្បីទទួលបានចំណេះដឹង និងចែករំលែកបន្ត ហើយគួរផ្តល់តម្លៃឱ្យសារព័ត៌មានវិជ្ជាជីវៈ។"



*ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន*

*© ខឹម សុវណ្ណារ៉ា / ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)*



លោក **ផាន ឥទ្ធបារមី**
នាយកគម្រោង អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា

“ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយមានការកើនឡើង ប៉ុន្តែសេរីភាពសារព័ត៌មាននៅកម្ពុជាមិនទាន់ល្អប្រសើរ។ ទោះយ៉ាងណាក្តី សារព័ត៌មានពលរដ្ឋបច្ចុប្បន្នមានការបញ្ចេញមតិ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងនោះក៏មានព័ត៌មានមិនពិតជាច្រើនផងដែរ។ ទន្ទឹមនេះមានការបញ្ចេញមតិប្រាសចាកក្រមសីលធម៌ផងដែរ។ ដើម្បីឱ្យសេរីភាពសារព័ត៌មាននៅកម្ពុជាកាន់តែល្អប្រសើរ រដ្ឋាភិបាលត្រូវពន្លឿនច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន បង្កើតច្បាប់ដោយឡែកការពារអ្នកសារព័ត៌មាន ពិនិត្យមើលច្បាប់ទាំងឡាយណាដែលប៉ះពាល់ដល់សេរីភាពសារព័ត៌មាន ធានាថាប្រព័ន្ធតុលាការឯករាជ្យ បង្កើនយន្តការស៊ើបអង្កេត និងឱ្យមន្ត្រីរដ្ឋាភិបាលទទួលខុសត្រូវចំពោះការរំលោភសេរីភាពសារព័ត៌មាន និងសិទ្ធិអ្នកសារព័ត៌មាន។ ”

## ៣. ស្ថានភាពសេរីភាពសារព័ត៌មានក្នុងក្របខណ្ឌច្បាប់

សេរីភាពសារព័ត៌មាន និងសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋ គឺជាសិទ្ធិមូលដ្ឋាន និងជាធាតុផ្សំដ៏សំខាន់ក្នុងសង្គមប្រជាធិបតេយ្យ។ សិទ្ធិ និងសេរីភាពទាំងនេះ ត្រូវបានធានាដោយច្បាប់កម្ពុជា និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលកម្ពុជាជាភាគីហត្ថលេខី ក្នុងក្របខណ្ឌដែលកម្ពុជាបាន និងកំពុងបន្តលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។ ដូចមានចែងក្នុង មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពក្នុងការជួបជុំ ត្រូវបានធានា និងការពារ។ ទន្ទឹមនេះដែរ ប្រទេសកម្ពុជាបាន និងកំពុងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាភាគីហត្ថលេខីនៃធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិនានាក្នុងការការពារ និងលើកស្ទួយការគោរពសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ជាងនេះទៀត រាជរដ្ឋាភិបាលកម្ពុជាទាំងក្នុងអាណត្តិមុនៗ និងអាណត្តិទី៧ បានបំពេញតួនាទីយ៉ាងសកម្មក្នុងការលើកកម្ពស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា ដោយអនុលោមតាមស្មារតីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេសដើម្បីធានាការការពារ និងគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន រាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួលនិងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមធ្យោបាយគ្រប់ទម្រង់ដោយគ្មានព្រំដែនកំណត់។







## មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ

"ប្រជាពលរដ្ឋខ្មែរមាន សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមដល់សណ្តាប់ធ្នាប់សាធារណៈនិងដល់សន្តិសុខជាតិឡើយ។"

អ្នកសារព័ត៌មាននៅកម្ពុជា ទាំងអ្នកសារព័ត៌មានជាតិ និងបរទេស កំពុងប្រកបវិជ្ជាជីវៈរបស់ខ្លួនក្នុងបរិយាកាសបើកទូលាយ ដោយមានការធានាលំហសេរីភាពស្របតាមច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥។ ទោះយ៉ាងណាក៏ដោយ អ្នកសារព័ត៌មានមកពីមជ្ឈដ្ឋាន និងគ្រប់និន្នាការដែលកំពុងប្រតិបត្តិការងារនៅក្នុងប្រទេសកម្ពុជា ត្រូវបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយគុណភាព សុក្រឹត្យភាព ដោយគោរពក្រមសីលធម៌វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវ មិនត្រូវឱ្យតួនាទីរបស់ខ្លួនបំពានលើសិទ្ធិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ និងដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## មាត្រាមួយចំនួននៃច្បាប់ និងបទដ្ឋានគតិយុត្ត ដែលចែងអំពីសិទ្ធិនិងភាតព្វកិច្ច

**មាត្រា២ ៖** សារព័ត៌មានមានសិទ្ធិរក្សាការសម្ងាត់ ស្តីពីប្រភពព័ត៌មានរបស់ខ្លួន។

**មាត្រា៣ ៖** ដើម្បីរក្សាឯករាជ្យនៃសារព័ត៌មាន ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយត្រូវហាមឃាត់។

**មាត្រា ១៧-១៨ ៖** កិច្ចការពារការប្រកួតប្រជែងដោយស្មើភាព និងការធានាចំពោះសារព័ត៌មានដែលកាន់កាប់ដោយជនបរទេស ដែលបានអនុញ្ញាតឱ្យចេញផ្សាយរួចហើយ មិនអាចត្រូវបិទដោយមូលហេតុថយចុះចំនួនសរុបទាំងអស់ នៃសារព័ត៌មានជាភាសាខ្មែរនោះទេ។

**មាត្រា២០ ៖** អំពើប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ ដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារដោយសារការបញ្ចេញមតិឡើយ។

**មាត្រា៣០៦ ៖** (អំពើបរិហាកេរ្តិ៍ តាមសារព័ត៌មាន)
ការបរិហាកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មានត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

**មាត្រា៣០៨ ៖** (អំពើជេរប្រមាថតាម សារព័ត៌មាន)
ការជេរប្រមាថដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន។



លោក **រ៉ាអ៊ូល ម៉ាក ជេណា**
អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ និងជាទីប្រឹក្សារាជរដ្ឋាភិបាល

> “ សេរីភាពនៃការបញ្ចេញមតិត្រូវបានប៉ះពាល់ដោយសារកង្វះការគោរពសិទ្ធិបុគ្គល កង្វះការគោរពច្បាប់ និងនៅពេលដែលមានការសាយភាយនូវព័ត៌មានក្លែងក្លាយ។ សេរីភាពនៃការបញ្ចេញមតិមិនមែនជាសេរីភាពជេរប្រមាថ និងបង្កាច់បង្ខូចផ្សព្វផ្សាយព័ត៌មានមិនពិត ឬបំពានច្បាប់នោះទេ។ សិទ្ធិរិះគន់សកម្មភាពឬការសម្រេចចិត្តរបស់រដ្ឋាភិបាលត្រូវតែធ្វើឡើងដោយឈរលើព័ត៌មានពិត និងគោរពសិទ្ធិបុគ្គល ចៀសវាងការប្រើពាក្យចចាមអារ៉ាម និងការវាយប្រហារលើឯកជនភាព។ អ្នកបញ្ចេញមតិទាំងឡាយត្រូវគោរពក្រមសីលធម៌នៃការសំដែងមតិជាសាធារណៈដែលស្ថិតក្នុងក្របខណ្ឌច្បាប់ ដើម្បីការពារអ្នកដទៃទៀតដែលប្រើសិទ្ធិនិងសេរីភាពនេះដោយគោរពច្បាប់ត្រឹមត្រូវ។ ”

## ៤. ការស្ទង់មតិស្តីពីស្ថានភាពសេរីភាពសារព័ត៌មានកម្ពុជា

ការស្ទង់មតិត្រូវបានអនុវត្តក្នុងរាជធានី-ខេត្តចំនួន២៥នៃព្រះរាជាណាចក្រកម្ពុជា ដោយបានផ្តល់កម្រងសំណួរសរុបចំនួន ៣៥០ កម្រងសំណួរ ទៅកាន់អ្នកសារព័ត៌មាន តាមវិធីសាស្ត្រ Random Sampling ពោលគឺអ្នកសារព័ត៌មាន ដែលបានចូលរួមក្នុងការស្ទង់មតិនេះ ត្រូវបានជួបដោយចៃដន្យ។ កម្រងសំណួរដែលយកជាការបានមានចំនួន ៣៤១ កម្រងសំណួរ។

អ្នកសារព័ត៌មានទាំងអស់ បានផ្តល់ព័ត៌មានចូលក្នុងកម្រងសំណួរដោយឯករាជ្យ អនាមិកភាព ផ្អែកតាមឆន្ទៈនិងការយល់ឃើញផ្ទាល់ខ្លួន ដោយគ្មានការត្រួតពិនិត្យ ឬស្ថិតក្រោមឥទ្ធិពលរបស់ជនណាម្នាក់ឡើយ។ លទ្ធផលនៃការស្ទង់មតិបានបង្ហាញថា អ្នកសារព័ត៌មាននៅកម្ពុជាភាគច្រើនជាបុរស ជាជនមានវ័យកណ្តាល មានអាយុ៤២ឆ្នាំជាមធ្យម ដោយក្នុងនោះអ្នកសារព័ត៌មានដែលមានអាយុចន្លោះពី ៣១ ដល់ ៤០ឆ្នាំ មានចំនួន ៣៤%និងអាយុចន្លោះពី ៤១ ដល់ ៥០ឆ្នាំ មានចំនួន ៣៣%។ ដោយឡែកអ្នកសារព័ត៌មានដែលមានអាយុចន្លោះពី២១ ដល់ ៣០ឆ្នាំ មានចំនួន ១០,៩% ហើយអ្នកសារព័ត៌មានដែលមានអាយុលើសពី ៥០ឆ្នាំ មានចំនួន ២១%។

តាមលទ្ធផលស្ទង់មតិ អ្នកសារព័ត៌មានដែលបានបញ្ចប់ថ្នាក់វិទ្យាល័យមានចំនួន ៤៣,៩% ហើយអ្នកសារព័ត៌មានចំនួនប្រមាណ ៣៣,៣% បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ខណៈអ្នកសារព័ត៌មានចំនួន ៦,២% បានបញ្ចប់ថ្នាក់ក្រោយឧត្តមសិក្សា។ ទោះជាយ៉ាងណាក៏ដោយ អ្នកសារព័ត៌មានចំនួន ៣,៥% មានកម្រិតវប្បធម៌ត្រឹមថ្នាក់បឋមសិក្សា

ប៉ុណ្ណោះ។ លទ្ធផលនៃការស្ទង់មតិបានបង្ហាញដែរថា អ្នកសារព័ត៌មានចំនួន ៩១,២% បានទទួលការបណ្តុះបណ្តាលផ្នែកសារព័ត៌មាន ក៏ប៉ុន្តែភាគច្រើននៃអ្នកសារព័ត៌មានទាំងនេះ ពោលគឺចំនួន ៩៧,១% បានទទួលការបណ្តុះបណ្តាលតាមរយៈការរៀនវគ្គខ្លីៗដែលបានរៀបចំដោយក្រសួងព័ត៌មាន ឬសមាគម/ក្លឹបសារព័ត៌មាន ខណៈអ្នកសារព័ត៌មានចំនួនត្រឹមតែ ២,២៥% ប៉ុណ្ណោះ បានទទួលការបណ្តុះបណ្តាលជំនាញពីសាកលវិទ្យាល័យ និង ០,៦៥% បានទទួលការបណ្តុះបណ្តាលនៅក្រៅប្រទេស។



*អ្នកសារព័ត៌មានកំពុងបំពេញការងាររបស់ខ្លួន © ហេង ជីវ័ន / ភ្នំពេញប៉ុស្តិ៍*

ពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មាន និងលំហសេរីភាពក្នុងការប្រកបការងារជាអ្នកសារព័ត៌មាននៅកម្ពុជា អ្នកសារព័ត៌មានចំនួន ៧៩,៨% យល់ថាប្រទេសកម្ពុជាមានសេរីភាពសារព័ត៌មានល្អប្រសើរ ដែលក្នុងចំណោមនោះ អ្នកសារព័ត៌មានចំនួន ៧១% ថាសេរីភាពសារព័ត៌មានមានស្ថានភាពល្អ ខណៈ ៨,៨% ថាមានស្ថានភាពល្អបំផុត។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមអ្នកស្ទង់មតិទាំងអស់ មានអ្នកសារព័ត៌មានចំនួន ៣,៥% បានយល់ថាសេរីភាពសារព័ត៌មាននៅមិនទាន់ល្អ និង ១៦,៧% មិនបានផ្តល់យោបល់ទេ។ អ្នកសារព័ត៌មានចំនួន ៧៩,៨% យល់ថាអ្នកសារព័ត៌មានមានសេរីភាពពេញលេញក្នុងការយកព័ត៌មានពីប្រភពនានា និងមានសេរីភាពពេញលេញក្នុងការផ្សព្វផ្សាយព័ត៌មានរបស់ខ្លួន ដោយអ្នកសារព័ត៌មានចំនួន ៧៧,១% បានឆ្លើយថា មិនមានការត្រួតពិនិត្យអត្ថបទ

មុនការផ្សព្វផ្សាយដោយអាជ្ញាធរមានសមត្ថកិច្ចទេ។ អ្នកសារព័ត៌មានចំនួន ៩៤,៤% យល់ថាប្រទេសកម្ពុជាមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសម្បូណ៌បែបដែលផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង ខណៈ អ្នកសារព័ត៌មាន ៩៥% បានឆ្លើយឯកភាពថាការមានប្រព័ន្ធផ្សព្វផ្សាយសម្បូណ៌បែបបានចូលរួមលើកកម្ពស់សេរីភាពសារព័ត៌មាននៅកម្ពុជា។

លទ្ធផលនៃការសិក្សាបានបង្ហាញទៀតថា អ្នកស្ទង់មតិចំនួន ៩៩,៧% បានឯកភាពលើសារៈសំខាន់ក្នុងការគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ក្នុងនោះ ៨១,៨% យល់ថាការគោរពក្រមសីលធម៌វិជ្ជាជីវៈមានសារៈសំខាន់ខ្លាំងណាស់។ ក្នុងទិដ្ឋភាពក្រមសីលធម៌វិជ្ជាជីវៈនេះដែរ អ្នកសារព័ត៌មានចំនួន ៩២,១% គាំទ្រឱ្យមានការអនុវត្តតាមនីតិវិធីច្បាប់ចំពោះអ្នកសារព័ត៌មានដែលប្រព្រឹត្តិខុសវិជ្ជាជីវៈ ហើយ ៩៩,៤% បានគាំទ្រការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មានដើម្បីពង្រឹងគុណភាពវិជ្ជាជីវៈ។ រីឯនៅក្នុងក្របខណ្ឌនៃការប្រឆាំងព័ត៌មានក្លែងក្លាយ អ្នកស្ទង់មតិចំនួន ៩៩,៤% យល់ថាអ្នកសារព័ត៌មានដើរតួនាទីសំខាន់ក្នុងកិច្ចការនេះ ខណៈ ៨១,២% យល់ថាតួនាទីរបស់អ្នកសារព័ត៌មានពិតជាសំខាន់ខ្លាំងណាស់ក្នុងការប្រឆាំងព័ត៌មានក្លែងក្លាយ។

ព័ត៌មាននិងលទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងនេះនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងប្រើប្រាស់ជាប្រភពព័ត៌មាន និងជាទិន្នន័យគោលមូលដ្ឋាន( baseline data ) សម្រាប់ការតាមដាន និងវាយតម្លៃស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជានៅឆ្នាំខាងមុខជាបន្តបន្ទាប់ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការបន្តលើកស្ទួយការអភិវឌ្ឍវិស័យព័ត៌មាន និងលើកកម្ពស់សេរីភាពសារព័ត៌មាននៅកម្ពុជាឱ្យកាន់តែរីកចម្រើនឡើង។




លោក **ស្លេះ ណាស៊ី**
ប្រធានមជ្ឈមណ្ឌលព័ត៌មានមូស្លីមកម្ពុជា

“ សេរីភាពសារព័ត៌មាននៅកម្ពុជាមានលក្ខណៈកាន់តែប្រសើរ ដោយសារបច្ចុប្បន្នមានអង្គភាពសារព័ត៌មានច្រើន ដែលជាមធ្យោបាយនៃការផ្តល់ព័ត៌មានដល់សាធារណៈជនគ្រប់មជ្ឈដ្ឋាន។ អ្នកសារព័ត៌មានត្រូវបានផ្តល់នូវតម្លៃនិងការពារដោយច្បាប់ដូចជាច្បាប់ស្តីពីរបបសារព័ត៌មាន។ សហគមន៍ចម្រុះនៅកម្ពុជាក៏មានមធ្យោបាយក្នុងការទទួលបានព័ត៌មានអំពីសហគមន៍ ជំនឿ និងការអប់រំសាសនាតាមភាសារបស់ជនជាតិនីមួយៗផងដែរ ដាក់ស្តែងព័ត៌មានសហគមន៍ខ្មែរឥស្លាម មានការផ្សាយជាភាសាចាមតាមវិទ្យុ គេហទំព័រ និងបណ្តាញសង្គម។ ”




យល់ថាខ្លួនឯងមានសេរីភាពពេញលេញ
ក្នុងការប្រមូលនិងផ្សព្វផ្សាយព័ត៌មាន




យល់ថាប្រទេសកម្ពុជា ជាប្រទេសមួយដែលមាន
ប្រព័ន្ធផ្សព្វផ្សាយសម្បូណ៌បែប




ឯកភាពថា ប្រព័ន្ធផ្សព្វផ្សាយសំបូរបែបនៅកម្ពុជាបច្ចុប្បន្ន គឺជា
ការចូលរួមលើកកម្ពស់សេរីភាពសារព័ត៌មាន




យល់ថាការគោរពក្រមសីលធម៌និងវិជ្ជាជីវៈសារព័ត៌មាន
ពិតជាមានសារៈសំខាន់ណាស់




គាំទ្រឱ្យក្រសួងអនុវត្តតាមនីតិវិធីច្បាប់ចំពោះអ្នកសារព័ត៌មាន
ដែលប្រព្រឹត្តិខុសក្រមសីលធម៌និងវិជ្ជាជីវៈសារព័ត៌មាន




យល់ឃើញថាអ្នកសារព័ត៌មានមានតួនាទីសំខាន់ខ្លាំង
ក្នុងការទប់ស្កាត់ព័ត៌មានក្លែងក្លាយ




គាំទ្រឱ្យមានការបណ្តុះបណ្តាលបន្ថែម ដើម្បីបង្កើនគុណភាព
ព័ត៌មាននៅកម្ពុជា

## ៥. កិច្ចគាំពារក្នុងវិស័យព័ត៌មាន និងសេវាសាធារណៈ

ការលើកកម្ពស់សុខុមាលភាពសម្រាប់អ្នកសារព័ត៌មានតាមរយៈកម្មវិធីគាំពារសង្គម ជាអាទិភាពដ៏ចម្បងមួយក្នុងក្របខណ្ឌនៃការអនុវត្តគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់អាណត្តិ។ អ្នកសារព័ត៌មានទាំងអស់ដែលប្រកបវិជ្ជាជីវៈរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានយកចិត្តទុកដាក់ពីសំណាក់ការអនុវត្តកម្មវិធីគាំពារនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ឬនិន្នាការនយោបាយអ្វីឡើយ។ ជាក់ស្ដែង ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ អ្នកសារព័ត៌មានទាំងអស់បានទទួលការចាក់វ៉ាក់សាំងដោយម៉ត់ចត់ និងគ្រប់ជូសនៅតាមវគ្គតម្រូវឱ្យទទួលវ៉ាក់សាំងនីមួយៗ ដើម្បីធានាថាអ្នកសារព័ត៌មានទាំងឡាយ ដែលបន្តការចុះយក និងផ្សាយព័ត៌មាន អាចបំពេញតួនាទីដ៏សំខាន់របស់ខ្លួនដោយសុវត្ថិភាព សម្រាប់ផ្សព្វផ្សាយព័ត៌មានពិត សុក្រឹត្យជូនដល់ប្រជាជននៅទូទាំងប្រទេស និងពិភពលោក នៅក្នុងគ្រាដ៏លំបាក និងប្រកបដោយភាពស្រពេចស្រពិលនៃស្ថានភាពនៃវិបត្តិសុខភាពពិភពលោកមួយនេះ។






*អ្នកសារព័ត៌មានជាតិ និងអន្តរជាតិតាមបណ្ដាស្ថាប័នសារព័ត៌មាននានានៅក្នុងប្រទេសកម្ពុជាមកទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃនៅទីស្ដីការក្រសួងព័ត៌មានថ្ងៃទី១ ខែមេសា ឆ្នាំ២០២១*

*© ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)*




*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងជំនួបរវាងនាយករដ្ឋមន្ត្រី ជាមួយអ្នកសារព័ត៌មាន ខែមករា ឆ្នាំ២០២៣ © ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)*

ជាមោទកភាពសម្រាប់ប្រជាជន និងជាតិកម្ពុជាទាំងមូល រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាត្រូវបានពិភពលោកផ្តល់ការទទួលស្គាល់លើភាពជោគជ័យក្នុងការគ្រប់គ្រងស្ថានភាពនៃវិបត្តិសុខភាពនេះ នៅក្នុងប្រទេសកម្ពុជាបានយ៉ាងល្អប្រសើរ និងជាប្រទេសទី១ក្នុងតំបន់អាស៊ាន ដែលបានកាត់បន្ថយការរាតត្បាតប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងដល់ប្រជាជននៅទូទាំងប្រទេសដោយឥតគិតថ្លៃ ទាន់ពេលវេលា និងដោយមិនបានរំលងប្រជាជនណាម្នាក់ឡើយ ដោយ អ្នកសារព័ត៌មាន ទាំងជាតិ និងអន្តរជាតិ ចំនួន ៦,១១៦នាក់ ស្ថិតនៅក្នុងក្រុមអាទិភាពក្នុងការទទួលបានវ៉ាក់សាំងការពារ។





*អ្នកសារព័ត៌មានជាតិ និងអន្តរជាតិតាមបណ្តាស្ថាប័នសារព័ត៌មាននានានៅក្នុងប្រទេសកម្ពុជាមកទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃនៅទីស្តីការក្រសួងព័ត៌មានថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ © ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)*

ការដឹកនាំប្រកបដោយបញ្ញាញាណ និងចក្ខុវិស័យវែងឆ្ងាយនេះ បានក្លាយជាគំរូដ៏ឧត្តុងឧត្តមសម្រាប់អ្នកដឹកនាំបន្តវេនក្នុងអាណត្តិទី៧នេះសម្រាប់ការគាំពារផ្នែកសុខាភិបាល។ តាមរយៈអនុស្សរណៈយោគយល់រវាងក្រសួងព័ត៌មាន និងមជ្ឈមណ្ឌលរោគវិនិច្ឆ័យប៊ីយ៉ូម៉េឌីក ( Biomedic ) ប្រតិបត្តិករក្នុងវិស័យព័ត៌មាន និងសោទស្សន៍ទាំងអស់ ទាំងរដ្ឋ និងឯកជន រាប់បញ្ចូលទាំងមន្ត្រីគ្រប់ថ្នាក់នៃក្រសួងព័ត៌មាន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ពីក្រសួង ព្រមទាំងសមាជិកក្រុមគ្រួសារផងដែរ អាចទទួលបានការបញ្ចុះតម្លៃ ៣០% សម្រាប់សេវាកម្មសុខភាពមួយចំនួនរបស់មជ្ឈមណ្ឌលរោគវិនិច្ឆ័យប៊ីយ៉ូម៉េឌីក ក្នុងគោលបំណងលើកទឹកចិត្តការថែរក្សា និងពិនិត្យសុខភាពជាប្រចាំ រួមចំណែកកាត់បន្ថយហានិភ័យសុខភាពសាធារណៈ និងលើកកម្ពស់ផលិតភាពការងារ។




*ពិធីចុះអនុស្សរណៈនៃការយោគយល់ស្តីពីការផ្តល់សេវាកម្មរោគវិនិច្ឆ័យ រវាងក្រសួងព័ត៌មាន និងមជ្ឈមណ្ឌលរោគវិនិច្ឆ័យប៊ីយ៉ូម៉េឌីក © ទីភ្នាក់ងារសារព័ត៌មានកម្ពុជា* (AKP)

ជាងនេះទៀត ដោយអនុវត្តនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការផ្តល់ការការពារផ្នែកច្បាប់ដោយក្រុមមេធាវីស្ម័គ្រចិត្ត **សម្តេចតេជោសែន** ជូនដល់អ្នកសារព័ត៌មានដែលទទួលរងនូវការចោទប្រកាន់ ឬជួបបញ្ហាផ្សេងៗក្នុងពេលអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដោយស្របច្បាប់។ ក្នុងកិច្ចការដ៏មានសារៈសំខាន់នេះ នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ក្រសួងព័ត៌មានបានចេញសេចក្តីសម្រេចបង្កើត «*គណៈកម្មការសម្របសម្រួលដោះស្រាយវិវាទរបស់អ្នកសារព័ត៌មាន*» ហើយជាលទ្ធផលក្នុងការអនុវត្តយន្តការនេះ ក្រសួងព័ត៌មានបានផ្តល់កិច្ចអន្តរាគមន៍សម្របសម្រួលការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ និងផ្តល់ប្រឹក្សាផ្នែកច្បាប់ដោយមានការគាំទ្រពីសំណាក់ក្រុមមេធាវីស្ម័គ្រចិត្ត**សម្តេចតេជោសែន** និងក្រុមមេធាវីស្ម័គ្រចិត្តរបស់ក្រសួងព័ត៌មានផងដែរ។ ជាក់ស្តែងក្នុងឆ្នាំ២០២៣ ក្រសួងបានទទួលដោះស្រាយវិវាទរបស់អង្គភាពសារព័ត៌មាន ចំនួន ៤៣លើក ដោយក្នុងនោះក្រសួងបានផ្តល់មេធាវីការពារក្តីទទួលបានជោគជ័យសរុបចំនួន ១១ ករណី និងបានផ្តល់ជំនួយប្រឹក្សាផ្នែកច្បាប់ដល់អង្គភាពសារព័ត៌មានសរុបចំនួន ៥០លើក ផ្សេងទៀត។








*កិច្ចប្រជុំពិនិត្យពិភាក្សាការងារ និងធ្វើបច្ចុប្បន្នភាពលើអនុស្សរណៈនៃការយោគយល់រវាងក្រសួងព័ត៌មាន និងក្រុមមេធាវីរបស់រាជរដ្ឋាភិបាល លើកិច្ចការពារផ្លូវច្បាប់ដល់អ្នកសារព័ត៌មាន ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣*
*© ខឹម សុវណ្ណារ៉ា / ទីភ្នាក់ងារសារព័ត៌មានកម្ពុជា* (AKP)

ទន្ទឹមនឹងនេះដែរដើម្បីរួមចំណែកកាត់បន្ថយសម្ពាធនៃការចំណាយរបស់អង្គភាពសារព័ត៌មាន ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងព័ត៌មាន ក៏ដូចជាលើកទឹកចិត្តឱ្យមានភាពប្រកួតប្រជែងក្នុងសម័យឌីជីថល រាជរដ្ឋាភិបាលបានអនុវត្តការលើកលែងពន្ធប៉ាតង់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៨ សម្រាប់សារព័ត៌មានអនឡាញប្រភេទធុនតូច ដោយរដ្ឋជាអ្នកទទួលបន្ទុកបង់ពន្ធនោះជំនួស។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានកាត់បន្ថយកម្រៃសេវាសម្រាប់ការស្នើសុំអាជ្ញាបណ្ណបង្កើតអង្គភាពសារព័ត៌មានថ្មីនៅក្រសួងព័ត៌មានចំនួន ៥០% ផងដែរ។ ម្យ៉ាងទៀត សម្រាប់អ្នកសារព័ត៌មានដែលមិនមានការិយាល័យប្រចាំការនៅឡើយជាពិសេសអ្នកសារព័ត៌មានទទួលកម្រៃតាមអត្ថបទ (Freelance Journalist) ក្រសួងបានរៀបចំ និងផ្តល់លទ្ធភាពក្នុងការភ្ជាប់អ៊ីនធឺណិតល្បឿនសមរម្យក្នុងបរិវេណនៃក្រសួងព័ត៌មាន សម្រាប់ប្រើប្រាស់ដោយឥតគិតថ្លៃ ដើម្បីសម្រួលការងាររបស់ខ្លួន។

ក្នុងក្របខណ្ឌនៃការលើកកម្ពស់ភាពងាយស្រួលមួយកម្រិតទៀតក្នុងការផ្តល់សេវាសាធារណៈ ក្រសួងព័ត៌មានបានរៀបចំកែលម្អការិយាល័យច្រកចេញចូលតែមួយ ដែលមានទីតាំងនៅទីស្តីការក្រសួងឱ្យមានភាពល្អប្រសើរ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣។ បច្ចុប្បន្ន សេវាសាធារណៈរបស់ក្រសួងព័ត៌មានរួមមាន៖ ការស្នើសុំលិខិតអនុញ្ញាតសម្រាប់ឃោសនាមហាជន ការស្នើសុំបើកអាជីវកម្មគ្រឹះស្ថានបោះពុម្ពផ្សាយ រោងពុម្ព សមាគមវិទ្យុ និងទូរទស្សន៍ អាជីវកម្មផ្សាយតាមប្រព័ន្ធអេឡិកត្រូនិក សេវាត្រួតពិនិត្យ អាជីវកម្មកាសែត (ភាសាជាតិ និងបរទេស) អាជីវកម្មទស្សនាវដ្តី អាជីវកម្មព្រឹត្តិប័ត្រភាសាជាតិ ការស្នើសុំប្តូរឈ្មោះកាសែត ការស្នើសុំផ្ទេរសិទ្ធិ

គ្រប់គ្រងស្ថាប័នសារព័ត៌មាន អាជីវកម្មនាំចូលកាសែត និងទស្សនាវដ្ដី ការស្នើសុំបង្កើតសមាគមព័ត៌មាន សាបង្កាន់ដៃ ស្នើសុំប័ណ្ណសារព័ត៌មានសម្រាប់អ្នកកាសែត និងសេវាកម្មសាធារណៈផ្សេងៗទៀតទាក់ទងនឹងសោតទស្សន៍។

លើសពីនេះ ក្រសួងព័ត៌មានបានធ្វើប្រតិភូកម្មមុខងារ នៃការស្នើសុំបន្តអាជ្ញាបណ្ណសារព័ត៌មានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ភាពងាយស្រួល និងបង្វិតការផ្តល់សេវាសាធារណៈទៅកៀកនឹងអ្នកប្រកបវិជ្ជាជីវៈសារព័ត៌មាន ព្រមទាំងរៀបចំឱ្យមានការផ្តល់សេវាសាធារណៈតាមប្រព័ន្ធអនឡាញផ្សេងៗទៀតផងដែរ។

នាពេលកន្លងទៅ ក្នុងក្របខណ្ឌនៃការអភិវឌ្ឍទំនាក់ទំនងល្អជាមួយអ្នកសារព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ក្រសួងព័ត៌មានបានសម្របសម្រួលការចូលរួម និងចុះយកព័ត៌មាន ដោយអ្នកសារព័ត៌មានជាតិ-អន្តរជាតិ ក្នុងព្រឹត្តិការណ៍ជាតិ-អន្តរជាតិដូចជា៖ កិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបលើកទី១៣ ដែលរៀបចំឡើងជាទម្រង់កូនកាត់ ( ផ្ទាល់ និងអនឡាញ ), កិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន, កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ, កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង លើកទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ, មហាសន្និបាតអន្តរសភាអាស៊ាន ( អាយប៉ា /AIPA ) លើកទី៤៣, ព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេមលើកទី៣២, ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២, ព្រឹត្តិការណ៍បោះឆ្នោតសកលនីតិកាលទី៧ នៃរដ្ឋសភា, ព្រមទាំងសម្របសម្រួលការចុះយកព័ត៌មានក្នុងព្រឹត្តិការណ៍ផ្លូវការនានារបស់ឥស្សរៈជនប្រមុខរដ្ឋ ប្រមុខរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ផ្សេងៗជាច្រើនទៀត។









*អ្នកសារព័ត៌មានមកទទួលបណ្ណសម្គាល់អត្តសញ្ញាណដែលមានភ្ជាប់ជាមួយនឹង QR Code និងប្រើប្រាស់សេវាសាធារណៈផ្សេងៗ នៅច្រកចេញចូលតែមួយនៃទីស្តីការក្រសួងព័ត៌មាន © ឡុង ដេវីត*







*តារាងតម្លៃសេវាសាធារណៈរបស់ក្រសួងព័ត៌មានដែលមានបង្ហាញនៅច្រកចេញចូលតែមួយ នៃទីស្តីការក្រសួងព័ត៌មាន © ឡុង ដេរីត*














*ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន ចុះត្រួតពិនិត្យការិយាល័យច្រកចេញចូលតែមួយ និងពន្យល់ពីសារៈសំខាន់នៃការដាក់* QR Code *លើបណ្ណសម្គាល់អត្តសញ្ញាណជូនអ្នកសារព័ត៌មានដែលបានមកទទួលបណ្ណ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ © ឡុង ដារីត*

# សេចក្តីសន្និដ្ឋាន



សេរីភាពសារព័ត៌មាននិងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ត្រូវបានលើកកម្ពស់ជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ហើយត្រូវបានយកចិត្តទុកដាក់ខ្លាំងឡើងបន្ថែមទៀតនៅក្នុងអាណត្តិទី៧នេះ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បន្តពី **សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី**។ នេះជាសក្ខីភាពបញ្ជាក់ពីគោលជំហរមុឹងម៉ាត់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារនិងលើកស្ទួយសេរីភាពសារព័ត៌មាននិងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍ច្បាប់ជាធរមាន។ សេរីភាពសារព័ត៌មាននិងសិទ្ធិសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា ត្រូវបានវាយតម្លៃថាមានភាពល្អប្រសើរ ហើយបាននិងកំពុងបោះជំហានទៅមុខ ជាវិជ្ជមានឥតឈប់ឈរស្របនឹងការវិវត្ត និងការរីកចម្រើននៃសង្គមកម្ពុជាទាំងមូល។ ជារួម តួអង្គសំខាន់ៗ និងភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យព័ត៌មាន បានបង្ហាញការកត់សម្គាល់របស់ខ្លួនលើភាពប្រែប្រួលជាវិជ្ជមាន ជាពិសេសការកែប្រែមុខមាត់ និងភាពជាអ្នកដឹកនាំរបស់ក្រសួងព័ត៌មានក្នុងអាណត្តិថ្មីជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងវិស័យព័ត៌មាននិងកិច្ចការសាធារណៈរបស់រដ្ឋ ព្រមទាំងបានផ្តល់ការសាទរចំពោះវឌ្ឍភាព និងលទ្ធផលការងារដែលក្រសួងព័ត៌មាន និងតួអង្គពាក់ព័ន្ធទាំងរដ្ឋនិងឯកជនរួមគ្នាសម្រេចបានក្នុងរយៈពេលប្រាំបីខែចុងក្រោយនេះ។ កិច្ចខិតខំទាំងអស់នេះបានបង្កើតជាបរិស្ថានល្អអំណោយផលសម្រាប់៖

១. ការអភិវឌ្ឍផ្នែកសមត្ថភាពស្ថាប័ននិងមូលធនមនុស្សក្នុងវិស័យព័ត៌មាន

២. ភាពរីកចម្រើនក្នុងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ទាំងប្រពៃណីនិងបែបទំនើប រួមទាំងមាតិកាផ្សាយប្រកបដោយលក្ខណៈចម្រុះ សម្បូណ៌បែប និងមានសណ្តាប់ធ្នាប់

៣. ការគ្រប់គ្រងសន្តិសុខព័ត៌មាននិងការប្រឆាំងព័ត៌មានក្លែងក្លាយទាំងក្នុងក្របខណ្ឌជំនាញ និងកិច្ចសហប្រតិបត្តិការ

៤. ការរៀបចំលិខិតបទដ្ឋានគតិយុត្តឱ្យស្របនឹងការវិវត្តក្នុងសង្គម ការពង្រឹងការអនុវត្តច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈដើម្បីធានាសណ្តាប់ធ្នាប់សារព័ត៌មានប្រកបដោយគុណភាព

៥. ការលើកកម្ពស់ភាពជាដៃគូដោយបរិយាប័ន្នជាមួយតួអង្គសំខាន់ៗ ដៃគូអភិវឌ្ឍន៍និងស្ថាប័នសារព័ត៌មាន សម្រាប់ការអភិវឌ្ឍវិស័យព័ត៌មាន និងសោតទស្សន៍ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាឱ្យកាន់តែរីកចម្រើនឡើង

ផ្អែកតាមទិន្នន័យក្រោមការគ្រប់គ្រងរបស់ក្រសួងព័ត៌មាន និងលទ្ធផលដែលទទួលបានពីការសិក្សានេះ អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មាននៅកម្ពុជាបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានយ៉ាងពេញលេញ និងពីគ្រប់ទិសទីទូទាំងប្រទេស។ អ្នកសារព័ត៌មានចំនួនប្រមាណមួយម៉ឺននាក់ ក្នុងនោះ ជាងប្រាំពាន់នាក់បានស្នើសុំបណ្ណសម្គាល់អ្នកសារព័ត៌មាន បាន និងកំពុងអនុវត្តការងារចុះយកព័ត៌មានដើម្បីផលិត និងផ្សព្វផ្សាយព័ត៌មានគ្រប់ទម្រង់តាមប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និងទំនើប នៅទូទាំងប្រទេសកម្ពុជា ព្រមទាំងបានធ្វើសេចក្តីរាយការណ៍ព័ត៌មាននានាបានដោយសេរី គ្រប់ពេលវេលា ដោយសុវត្ថិភាព អនុលោមតាមវិជ្ជាជីវៈ និងក្រមសីលធម៌ក្នុងវិស័យព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងព័ត៌មានព្រួយបារម្ភអំពីនិន្នាការថមថយនៃប្រព័ន្ធផ្សព្វផ្សាយប្រពៃណី ជាពិសេសស្របពេលដែលសារព័ត៌មានបោះពុម្ព និងវិទ្យុមួយចំនួនបានបញ្ឈប់ដំណើរការផ្សាយរបស់ខ្លួននាពេលថ្មីៗកន្លងទៅនេះ ដូចជាកាសែតរស្មីកម្ពុជា និងកាសែតភ្នំពេញប៉ុស្តិ៍ជាភាសាខ្មែរ និងអង់គ្លេស។ ស្ថានភាពអាក្រក់នេះបានកើតឡើងជាផលវិបាកមួយចេញពីរបត់នៃបរិវត្តកម្មឌីជីថលដែលប្រទេសកម្ពុជា និងប្រទេសទាំងអស់នៅលើពិភពលោកបានជួបប្រទះ និងកំពុងប្រឈម។

ក្នុងអាណត្តិទី៧នេះ ក្រសួងព័ត៌មាន ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់លើការផ្តល់ការគាំពារ និងការការពារសិទ្ធិដល់អ្នកសារព័ត៌មានដែលបានចុះបញ្ជីនៅក្រសួងព័ត៌មាន ក្នុងករណីជួបប្រទះនឹងបញ្ហាក្នុងពេលបំពេញការងាររបស់ខ្លួនដោយបានគោរព និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ។ អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានដែលបានទទួលកិច្ចគាំពារ និងការការពារតាមផ្លូវច្បាប់ពីក្រសួងព័ត៌មាន បានបង្ហាញការពេញចិត្ត និងការថ្លែងអំណរគុណចំពោះក្រសួងព័ត៌មាន និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងចម្បងគឺលើកតម្កើងតម្លៃវិជ្ជាជីវៈ ការពារអាជីពអ្នកសារព័ត៌មាន និងលើកស្ទួយសេរីភាពសារព័ត៌មាននៅកម្ពុជា។



លោក **ស៊ុយ សែ**

តំណាងការិយាល័យទីភ្នាក់ងារសារព័ត៌មាន AFP

“ដើម្បីធ្វើអោយសេរីភាពសារព័ត៌មាននៅប្រទេសកម្ពុជាប្រសើរឡើង ស្ថាប័នទាំងអស់គួរស្វែងយល់សារៈសំខាន់នៃការផ្សព្វផ្សាយព័ត៌មាន និងតួនាទីអ្នកសារអាជីពមានវិជ្ជាជីវៈ។ នៅមានលទ្ធភាពធ្វើអោយប្រសើរឡើងពីសំណាក់ស្ថាប័នរដ្ឋ និងអាជ្ញាធរមូលដ្ឋាននៅពេលមានការស្នើសុំពីអ្នកសារព័ត៌មានក្នុងការសហការផ្តល់ព័ត៌មានអោយបានទាន់ពេលវេលា។”



*អ្នកសារព័ត៌មានកំពុងរង់ចាំយកព័ត៌មាន © ភ្នំពេញប៉ុស្តិ៍*



លោក **អ៊ុច ប៊ុនអ៊ី**
ប្រធានដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ
និងសារគមនាគមន៍ (DMC)

“ សេរីភាពសារព័ត៌មាននៅកម្ពុជានៅមានកម្រិតនៅឡើយ។ ដើម្បីឱ្យសេរីភាពសារព័ត៌មាននៅកម្ពុជាកាន់តែល្អប្រសើរឡើង ត្រូវអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដើម្បីជួយសម្រួលដល់ដំណើការប្រមូល ទទួលបាន និងផ្សព្វផ្សាយព័ត៌មាន, ពង្រឹងសមត្ថភាពវិជ្ជាជីៈរបស់អ្នកសារព័ត៌មានដែលកំពុងតែបំពេញការងារបច្ចុប្បន្ន, បង្កើនចំនួនអ្នកសារព័ត៌មានដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវឱ្យកាន់តែច្រើនថែមទៀត, ធ្វើកំណែទម្រង់ច្បាប់ស្តីពីរបបសារព័ត៌មានដើម្បីធានាឱ្យបាននូវសិទ្ធិសេរីភាពខាងសារព័ត៌មានឱ្យស្របតាមបទដ្ឋានអន្តរជាតិ និងស្របតាមបរិបទប្រព័ន្ធផ្សព្វផ្សាយដែលមានការរីកចម្រើនឥតឈប់ឈរ, ពង្រឹងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានដល់សាធារណជនទូទៅ ។ ”



# អនុសាសន៍

ជាមួយនឹងការវិវត្តដ៏ឆាប់រហ័សនៃប្រព័ន្ធផ្សព្វផ្សាយ ក្រសួងព័ត៌មានសូមលើកទឹកចិត្តដល់តួអង្គពាក់ព័ន្ធទាំងអស់ឱ្យបន្តអភិវឌ្ឍសមត្ថភាពរបស់ខ្លួន និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលនៃការរីកចម្រើននៃបច្ចេកវិទ្យាដើម្បីលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាព រក្សាបាននូវភាពប្រកួតប្រជែង និងអត្តសញ្ញាណរបស់ខ្លួន។ បេសកកម្មដ៏សំខាន់នេះ ចាំបាច់ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តអភិវឌ្ឍធនធានមនុស្ស បង្កើនជំនាញបច្ចេកទេស ចំណេះដឹង និងចំណេះធ្វើ ដើម្បីបំពេញការងារប្រកបដោយគុណាធិបតេយ្យប្រសិទ្ធភាព និងបរិយាប័ន្នក្នុងវិស័យព័ត៌មាន រាប់បញ្ចូលទាំងការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងប្រទេស តំបន់ និងជាមួយបណ្តាប្រទេសនៅលើពិភពលោក សំដៅពង្រឹងគុណភាព បណ្តុះភាពធន់ លើកកម្ពស់ក្រមសីលធម៌ និងចូលរួមក្នុងការប្រឆាំងព័ត៌មានក្លែងក្លាយ ដើម្បីរួមចំណែកការពារថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា។

ក្រសួងព័ត៌មាន ក្នុងនាមជាស្ថាប័នកិច្ចការសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តតួនាទី និងបេសកកម្មរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ ដោយផ្តោតលើការពង្រឹង និងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងប្រព័ន្ធផ្សព្វផ្សាយបុរាណ និងទំនើបរបស់ជាតិ និងឯកជន ដើម្បីធានាការទទួលបានព័ត៌មានពិតគ្រប់ជ្រុងជ្រោយ ពីសំណាក់ប្រជាជននៅគ្រប់ទិសទី តាមតម្រូវការ និងទាន់ហេតុការណ៍ ដោយផ្អែកលើអភិក្រម ***«ថ្មី ពិត លឿន និងទូលំទូលាយ ប្រកបដោយជំនឿទុកចិត្តនិងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន»*** ព្រមទាំងសម្រាប់ត្រៀមខ្លួនក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឌីជីថល និងបដិវត្តឧស្សាហកម្មជំនាន់ទី៤។ ក្នុងន័យនេះ ដើម្បីចូលរួមអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងព័ត៌មានបានដាក់ចេញនូវទិសដៅការងារឆ្នាំ២០២៤ ដោយកំណត់នូវអាទិភាពសំខាន់ៗ និងទិសដៅយុទ្ធសាស្ត្រទាំង៥ គឺ៖

១. ការធ្វើទំនើបកម្មស្ថាប័ន និងការកសាងរដ្ឋបាលទំនើប

២. ការពង្រឹងបទដ្ឋានបច្ចេកទេស និងការទទួលខុសត្រូវវិជ្ជាជីវៈ

៣. ការអភិវឌ្ឍធនធានមនុស្ស និងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ

៤. ការរៀបចំប្រព័ន្ធ និងយន្តការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន

៥. ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព

ក្នុងក្របខណ្ឌនៃការរៀបចំ និងពង្រឹងការគ្រប់គ្រងសណ្ដាប់ធ្នាប់សារព័ត៌មាន ក្រសួងព័ត៌មានបានដាក់ចេញទិសដៅក្នុងការរៀបចំប្រព័ន្ធ និងយន្តការគ្រប់គ្រងព័ត៌មាន លំហព័ត៌មាន និងសន្តិសុខព័ត៌មាន និងការប្រឆាំងព័ត៌មានក្លែងក្លាយដោយជំរុញសុក្រឹត្យភាព និងប្រសិទ្ធភាពការងារ ដើម្បីធានាសិទ្ធិទទួលព័ត៌មាន គុណភាពព័ត៌មាន និងសុវត្ថិភាពក្នុងការប្រើប្រាស់ព័ត៌មាន។ ក្រសួងព័ត៌មានបាន និងកំពុងបន្តពិនិត្យឡើងវិញលើការកសាងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឱ្យស្របតាមបរិបទសង្គមដូចជាៈ ពិនិត្យនិងរៀបចំឡើងវិញច្បាប់ស្តីពីរបបសារព័ត៌មានដើម្បីឆ្លើយតបនឹងការវិវត្តក្នុងសង្គមបច្ចុប្បន្ន និងទៅអនាគត, ធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន ក៏ដូចជាបទដ្ឋានពាក់ព័ន្ធនានា, ការតាក់តែង *«ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន»* សម្រាប់ជាគោលការណ៍ប្រតិបត្តិស្តង់ដានៃក្រមសីលធម៌សារព័ត៌មានសំដៅពង្រឹងប្រសិទ្ធភាពស្ថាប័ននិងគុណភាពការងារសារព័ត៌មានជានាការអនុវត្តក្រមសីលធម៌ក្នុងការផ្សព្វផ្សាយព័ត៌មាននិងការផ្សព្វផ្សាយពាណិជ្ជកម្ម, ពិនិត្យនីតិវិធី និងពង្រឹងដំណើរការក្នុងការចេញបណ្ណសម្គាល់អ្នកសារព័ត៌មានដោយក្រសួងព័ត៌មានតាមប្រព័ន្ធអនឡាញ ដោយមានភ្ជាប់ប្រព័ន្ធ QR Code ដើម្បីធានាភាពស្របច្បាប់និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះដែរ ក្រសួងព័ត៌មាននឹងរៀបចំបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងស្ថិតិប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្តនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មព័ត៌មាននិងសោតទស្សន៍ និងដើម្បីឈានទៅវាយតម្លៃស្ថានភាព និងធ្វើបច្ចុប្បន្នភាពសារព័ត៌មាននៅកម្ពុជា។ ជាងនេះទៀត ក្រសួងព័ត៌មាននឹងបន្តរៀបចំឡើងនូវវេទិកាផ្សេងៗ រាប់បញ្ចូលទាំងជំនួបប្រចាំឆ្នាំរវាង **សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងអ្នកសារព័ត៌មាន វេទិកាផ្លាស់ប្តូរមតិយោបល់ជាមួយសមាគមសារព័ត៌មាន និងអ្នកសារព័ត៌មាន ក្នុងគោលបំណងលើកកម្ពស់ភាពជាដៃគូក្នុងការអភិវឌ្ឍវិស័យព័ត៌មានឱ្យមានភាពរីកចម្រើនឡើងថែមទៀត ព្រមទាំងដើម្បីបង្កើនមនសិការស្រឡាញ់ និងការពារអាជីពអ្នកសារព័ត៌មាន ដោយគោរពក្រមសីលធម៌ និងលើកតម្កើងតម្លៃវិជ្ជាជីវៈសារព័ត៌មានកម្ពុជាឱ្យកាន់តែមានការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

ក្រសួងព័ត៌មានសូមអំពាវនាវដល់អង្គភាពសារព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ឱ្យបន្តលើកកម្ពស់ការគោរពក្រមសីលធម៌វិជ្ជាជីវៈ អនុវត្តតួនាទីនិងភារកិច្ចដោយគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ក៏ដូចជាកសាង និងរក្សាទំនាក់ទំនងល្អជាមួយប្រភពព័ត៌មាន ក្នុងនោះមានអ្នកនាំពាក្យតាមក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងភាគីផ្សេងៗទៀត ដោយត្រូវបំពេញភារកិច្ចខ្លួនក្នុងក្របខណ្ឌដែលច្បាប់កំណត់ និងមិនត្រូវអនុវត្តលើសពីតួនាទីខ្លួនជាអ្នកសារព័ត៌មាននោះទេ។ ជាងនេះទៀត អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានត្រូវចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានពិត ជាមួយខ្លឹមសារប្រកបដោយគុណភាព ពោលគឺជាព័ត៌មានគ្រប់ជ្រុងជ្រោយ មានប្រភពច្បាស់លាស់ ខ្លឹមសារប្រកបដោយតុល្យភាពព័ត៌មាន ដើម្បីធានាភាពជឿជាក់ ទុកចិត្តបានពីសំណាក់ប្រជាជន សង្គមជាតិទាំងមូល និងលើកកម្ពស់វិស័យព័ត៌មានជាអំណាចទី៤ ក្នុងការរួមចំណែកដល់ការការពារថែរក្សាសុខសន្តិភាពនៅកម្ពុជា និងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ ក្រសួងព័ត៌មានបន្តលើកកម្ពស់គុណភាពវិជ្ជាជីវៈ និងបានត្រៀមខ្លួនរួចជាស្រេចក្នុងការសហការជាមួយសមាគមសារព័ត៌មានទាំងអស់ ក្នុងការពង្រឹងសមត្ថភាពជំនាញតាមរយៈការបណ្តុះបណ្តាលជំនាញនិពន្ធ ផលិត និងផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាព និងបំពាក់បំប៉នជូនដល់អ្នកសារព័ត៌មាននូវចំណេះដឹងស្តីពីក្រមសីលធម៌ក្នុងវិស័យព័ត៌មានឱ្យកាន់តែប្រសើរ។

ក្រសួងព័ត៌មានក៏សូមអំពាវនាវផងដែរដល់ប្រទេសជាអ្នកផ្តល់ជំនួយទាំងឡាយ ដែលកំពុងមានកិច្ចសហការនៅក្នុងប្រទេសកម្ពុជា ឬគ្រោងនឹងបង្កើតកិច្ចសហការជាដៃគូក្នុងរូបភាពជាជំនួយបច្ចេកទេស ឬតាមរយៈការផ្តល់មូលនិធិក្តី ត្រូវគោរពដាច់ខាតនូវអធិបតេយ្យភាព និងឯករាជភាពរបស់កម្ពុជា ហើយត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការនោះក្នុងក្របខណ្ឌរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យព័ត៌មាន ដើម្បីបម្រើប្រយោជន៍របស់ប្រជាជន និងជាតិកម្ពុជាទាំងមូល។ ក្រសួងព័ត៌មានក៏សូមអំពាវនាវយ៉ាងទទូចដល់ប្រទេសជាអ្នកផ្តល់ជំនួយទាំងឡាយ ឱ្យប្រកាន់ខ្ជាប់នូវសច្ចៈភាព អព្យាក្រឹតភាព និងការទទួលខុសត្រូវខ្ពស់ក្នុងគម្រោងសហប្រតិបត្តិការរបស់ខ្លួន ដោយមិនត្រូវភ្ជាប់ការផ្តល់ជំនួយនោះ ទោះក្នុងរូបភាពជាការគាំទ្របែបបច្ចេកទេសឬការផ្តល់មូលនិធិក្តី ទៅនឹងរបៀបវារៈផ្សេងដែលអាចជះឥទ្ធិពលមកលើភាពជាម្ចាស់ និងឯករាជភាពរបស់កម្ពុជា ហើយដើម្បីទាញយកសារព័ត៌មាននេះជាមធ្យោបាយក្នុងការបម្រើឱ្យនយោបាយរបស់ខ្លួនឡើយ។ កម្ពុជាចង់បានការចូលរួម និងកិច្ចសហការដោយភាពស្មោះត្រង់ ប្រកបដោយគុណភាព និងទទួលខុសត្រូវ ដើម្បីគាំទ្រដល់ការរីកចម្រើន និងកំណើនប្រកបដោយនិរន្តរភាពក្នុងវិស័យព័ត៌មាននៅកម្ពុជា។



*អ្នកសារព័ត៌មានយកព័ត៌មាននៅក្នុងសិក្ខាសាលាស្តីពី «ប្រសិទ្ធភាពនៃកិច្ចការនាំពាក្យព័ត៌មាន និងសាធារណមតិ» នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា © ភ្នំពេញប៉ុស្តិ៍*




# ចក្ខុវិស័យគ្រប់គ្រង វិស័យសារព័ត៌មាននៅកម្ពុជា

លទ្ធផលនៃការសិក្សានេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីភាពរីកចម្រើននៃវិស័យព័ត៌មាន និងការអភិវឌ្ឍកាន់តែប្រសើរឡើងនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ប្រកបដោយលក្ខណៈចម្រុះនិងសម្បូណ៌បែប ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជាពីមួយអាណត្តិទៅមួយអាណត្តិ។ អ្នកសារព័ត៌មានបាន និងកំពុងបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានយ៉ាងពេញលេញ យ៉ាងសកម្មពីគ្រប់ទិសទីនៅទូទាំងប្រទេស ក្នុងការចុះយកព័ត៌មាន ផលិត និងផ្សព្វផ្សាយព័ត៌មានគ្រប់ទម្រង់ ក៏ដូចជាធ្វើសេចក្តីរាយការណ៍ព័ត៌មាននានាដោយសេរី គ្រប់ពេលវេលា ដោយសុវត្ថិភាព តាមវិជ្ជាជីវៈខ្លួនដោយតម្លាភាព ហើយទទួលបានការទុកចិត្ត និងការគាំទ្រពីសាធារណជនទូទៅគ្រប់មជ្ឈដ្ឋានទាំងអស់។ ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ និងឯកជនពិតជាដើរតួនាទីសំខាន់ ជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គម ដោយបាននិងកំពុងរួមចំណែកក្នុងការធានានូវសិទ្ធិទទួលព័ត៌មាន និងសិទ្ធិដឹងរបស់សាធារណជន និងចូលរួមផ្តល់ជាបច្ច័យដល់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការដោះស្រាយបញ្ហាក្នុងមូលដ្ឋានរបស់ខ្លួនទាន់ពេលវេលា សម្រាប់បម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា។

ក្រសួងព័ត៌មានបានកំណត់ចក្ខុវិស័យរបស់ខ្លួនជា *«ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយភាពសកម្ម បុរេសកម្ម អន្តរសកម្ម ប្រសិទ្ធភាពនិងគុណភាព»* ដើម្បីចូលរួមចំណែកថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ។ ដើម្បីសម្រេចចក្ខុវិស័យនេះ ក្រសួងព័ត៌មានបានដាក់ចុះនូវការដ្ឋានជាច្រើនក្នុងការបន្តកំណែទម្រង់ស៊ីជម្រៅ ដោយផ្តោតលើការធ្វើទំនើបកម្មស្ថាប័ន និងរដ្ឋបាលទំនើប ពង្រឹងប្រសិទ្ធភាពស្ថាប័ន និងគុណភាពការងារ ការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ការពង្រឹងការអនុវត្តច្បាប់ និងសហប្រតិបត្តិជាមួយដៃគូ កិច្ចគាំពារមន្ត្រី និងដោយប្រកាន់គោលការណ៍គុណាធិបតេយ្យ និងមានសមត្ថភាពផ្តល់នូវការលើកទឹកចិត្ត។ មិនតែប៉ុណ្ណោះ ក្រសួងព័ត៌មានបាន និងកំពុងខិតខំរៀបចំសណ្តាប់ធ្នាប់ក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ និងពង្រឹងសន្តិសុខព័ត៌មានដោយផ្តោតជាសំខាន់លើការធានានូវសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ គុណភាពព័ត៌មាន និងសុវត្ថិភាពព័ត៌មាន។ សុវត្ថិភាពព័ត៌មានជាសសរស្តម្ភដ៏មានសារៈសំខាន់ក្នុងការពង្រឹងសន្តិសុខព័ត៌មាន និងលើកកម្ពស់វិស័យព័ត៌មាននៅកម្ពុជា ក្នុងគោលបំណងដើម្បីទប់ស្កាត់និងប្រឆាំងព័ត៌មានក្លែងក្លាយ និងពង្រឹងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន ខណៈប្រព័ន្ធផ្សព្វផ្សាយទំនើបបាននិងកំពុងដើរតួនាទីជាប្រភពព័ត៌មានសំខាន់សម្រាប់សាធារណជន។

ក្នុងអាណត្តិទី៧នេះ ក្រសួងព័ត៌មានបានប្តេជ្ញាចិត្តបន្តពូនជ្រុំកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលក្នុងវិស័យព័ត៌មាន ដើម្បីលើកតម្កើង និងការពារសេរីភាពសារព័ត៌មាន សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការទទួលព័ត៌មាន ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ទន្ទឹមនេះ ក្រសួងព័ត៌មាននឹងបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការធានា និងរក្សានូវបរិយាកាសប្រកបដោយសុវត្ថិភាពសម្រាប់ការប្រកបវិជ្ជាជីវៈសារព័ត៌មាននៅកម្ពុជា ដោយបន្តលើកកម្ពស់ការគោរពសិទ្ធិសេរីភាពសារព័ត៌មាន ដោយឈរលើមូលដ្ឋានសមភាព គ្មានការរើសអើង គ្មានការគំរាមកំហែង និងមិនប្រកាន់និន្នាការនយោបាយឡើយ ខណៈបន្តពង្រឹងបច្ចុប្បន្នភាពនៃច្បាប់ និងលិខិតបទដ្ឋានសម្រាប់វិស័យព័ត៌មាន ដើម្បីធានាការការពារសិទ្ធិ សណ្តាប់ធ្នាប់ ការគ្រប់គ្រងនូវគុណភាព និងសុវត្ថិភាព

ព័ត៌មាន។ មិនតែប៉ុណ្ណោះ ក្រសួងនឹងបន្តលើកកម្ពស់ភាពចម្រុះក្នុងមុខងារ និងការប្រកបរបរសារព័ត៌មាន ដោយបន្តលើកកម្ពស់សិទ្ធិ និងលើកទឹកចិត្តការចូលរួមរបស់ស្ត្រីតាមរយៈការបង្កើតប្រព័ន្ធកូតាសម្រាប់អ្នកសារព័ត៌មានជាស្ត្រី។ ជាងនេះទៀត ក្រសួងនឹងបន្តលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នកសារព័ត៌មាន ព្រមទាំងធានាការបង្កបរិយាកាសការងារល្អ និងបង្កើតមធ្យោបាយទំនាក់ទំនងនានាអំណោយផលដល់ការសហការកាន់តែប្រសើររវាងអ្នកសារព័ត៌មាន និងស្ថាប័នសាធារណៈ ក៏ដូចជាបន្តផ្តល់នូវការគាំពារដល់អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានដែលបានចុះបញ្ជីទាំងអស់ ទាំងផ្នែកផ្លូវច្បាប់ សុខុមាលភាព និងសេវាសាធារណៈទាក់ទងនឹងវិស័យព័ត៌មាន។ តាមរយៈការដាក់ចេញនូវចក្ខុវិស័យ និងគោលការណ៍អាទិភាពជាមាគ៌ាសម្រាប់ការអនុវត្តទាំងនេះ ក្រសួងព័ត៌មានកំពុងរួមចំណែកយ៉ាងសកម្មក្នុងបេសកកម្ម និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំពារសិទ្ធិ សេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ដោយលើកកម្ពស់ស្ថាប័នសារព័ត៌មានជាដៃគូមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងលទ្ធិប្រជាធិបតេយ្យឱ្យកាន់តែរីកចម្រើនឡើងថែមទៀត។

អ្នកសារព័ត៌មានជាអ្នកពាំពាក្យ និងព័ត៌មានពិតពីក្នុងសង្គមកម្ពុជា ទៅកាន់ប្រជាជននៅទូទាំងប្រទេស និងលើពិភពលោក។ ក្នុងន័យនេះ ក្រសួងព័ត៌មានសូមបន្តលើកទឹកចិត្តដល់អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានទាំងអស់នៅកម្ពុជា ឱ្យបំពេញតួនាទីជាអ្នកតាមដានការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយឈរលើមូលដ្ឋានវិជ្ជាជីវៈ និងមនសិការទទួលខុសត្រូវ ប្រកាន់ខ្ជាប់នូវការអនុវត្តក្រមសីលធម៌សារព័ត៌មាន ដើម្បីផ្តល់ព័ត៌មានជូនដល់សាធារណជន និងអាជ្ញាធរ និងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាឱ្យទាន់ពេលវេលាសម្រាប់ជាប្រយោជន៍ដល់ប្រជាជន និងជាតិកម្ពុជាទាំងមូល។ ជាងនេះទៀត ក្នុងបរិបទនៃសង្គមព័ត៌មានឌីជីថល អ្នកសារព័ត៌មានជាតួអង្គដ៏សំខាន់មួយក្នុងសង្គមក្នុងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ដោយប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវចំពោះតួនាទីនិងភារកិច្ចរបស់ខ្លួន បង្កើនការផ្សព្វផ្សាយព័ត៌មានពិត និងបង្កើតមាតិកាមានគុណភាព ពោលគឺជាព័ត៌មានគ្រប់ជ្រុងជ្រោយ ដែលមានប្រភពច្បាស់លាស់ ខ្លឹមសារមានតុល្យភាពព័ត៌មាន និងធ្វើសេចក្តីរាយការណ៍ព័ត៌មានដែលជឿទុកចិត្តបានពីគ្រប់មជ្ឈដ្ឋាន ដើម្បីផ្តល់ដំណឹងចំណេះដឹង ការអប់រំ ដែលរួមចំណែកក្នុងការកាត់បន្ថយព័ត៌មានបែបបំពុល និងព័ត៌មានក្លែងក្លាយពីក្នុងលំហព័ត៌មាន និងចូលរួមក្នុងការការពារសន្តិសុខព័ត៌មាននៅកម្ពុជា៕




ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building 62, Monivong BLVD,Sangkat Srah Chork,
Khan Daun Penh, Phnom Penh